# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូបញ្ញាលិក្ខិត កៅ-ស៊ុម អ្នកត្រួតត្រា
សិស្ស នៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* ទំព័រ

ស្មៀន គង់-សន . . . . . . . ពាក្យសុភាសិតបុរាណ . . . . . . . . . ៩០៥

ឃុនឧត្ដមប្រីជា បាច-ពិន . . បណ្ដាំ (តមក) . . . . . . . . . . . ៩០៨

លោក ហាន់-យេង . . . . . . រឿងកំពូលកំសត់ (តមក) . . . . . . . . ៩១៦

លោក ញ៉ុក-នូរ . . . . . . ច្បាប់ក្រមបរិយាយ (តមកនិងចប់) . . . . ៩៣០

*ផ្នែកសាសនា*

ដំណឹងអំពីក្រសួងធម្មការ . . . អំពីហៅអធិការនិងមន្ត្រីសង្ឃ ដែលទើបតាំងថ្មី ៩៤៨

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម . . . ឯកភាគនៃមិលិន្ទប្បញ្ហា (តមក) . . . . . ៩៥៣

ឆ្នាំទី ១៦ — លេខ ១០ ខែឧកតូប្រ៍ ឆ្នាំ ១៩៤៤ — ដំឡៃជាវៈ ១ ឆ្នាំ ១៥ រៀល ។

N° 10

M.8° 1461
27-XI-44

# KĂMPŬCHĔASŎRĬYA

Revue religieuse et littéraire éditée par l'Institut Bouddhique.
Rédacteur en chef de la partie littéraire : Luong Nibandhamantri NHOK-THÊM, Pandit à l'Institut Bouddhique.
Rédacteur en chef de la partie religieuse : Preah kru Paññalikhito KAO-SIM, Surveillant général de l'École Supérieure de Pāli.

## TABLE DES MATIÈRES

### Partie littéraire:

| | | Pages |
|---|---|---|
| Smien Kong-Sân . . . . | Peak sŏp'easĕt bŏran. . . . . . | 505 |
| K'ŭn Ŏtdăm Preichea Chap-Pinn . . . . . . . | Băndau (devinettes cambodgiennes) | 508 |
| Monsieur Han-Yéng. . . . | Kămpul kămsăt, roman (suite) . . | 516 |
| Monsieur Nheuk-Nou. . . | Chbáp krăm bârĭyay (suite et fin) | 530 |

### Partie religieuse:

| | | |
|---|---|---|
| Communiqué du Département des Cultes . . . | Nominations de Chau At'ikar et Montrei săng . . . . . . . . | 548 |
| Luong Nĭponmontrei Nhok-Thêm . . . . . . . | Ekabhāga-Milindapañhā (suite). . . | 557 |

16e année — No 10. Octobre 1944 — Abonnement : un an 15$00.

# ពាក្យសុភាសិតបុរាណ

ខ្ញុំបាទ សៀនគង់-សន ផ្ទះនៅផ្លូវជេសបុស លេខ ៥៦ ឃុំលេខ ៥ ក្រុងភ្នំពេញ ។ កាលខ្ញុំបាទនៅពីក្មេង (ក្នុងរជ្ជកាលព្រះបាទសម្តេចព្រះនរោត្តម ព្រះករុណា សុវណ្ណកោដ្ឋ) នោះខ្ញុំបាទបានធ្វើដំណើរចេញពីស្រុកខ្មែរទៅស្រុកកូស័ងស៊ីន បានចូលទៅសំណាក់នៅវត្តមួយហៅថា វត្តចង់បត់ នៅក្នុងខែត្រព្រែកឫស្សី បានប្រទះឃើញសាស្ត្រាស្លឹករឹត ១ ខ្សែ រេចដាច់ដាចអស់ហើយនៅសល់តែបីសន្លឹក សេចក្តីក្នុងសាស្ត្រានោះជាពាក្យកាព្យហើយជាពាក្យសុភាសិត ខ្ញុំបាទចាប់យកមកមើលឃើញមានសេចក្តីពីរោះស្តាប់ ចាប់ដល់ត្រចៀកខ្ញុំបាទពន់ពេក ទើបខំទន្ទេញចាំលុះតែចាំមាត់ ។ ឯពាក្យជំបូន្មានទាំងនេះ មាននៅក្នុងច្បាប់អ្វី ឬសាស្ត្រាអ្វី ខ្ញុំមិនដែលប្រទះឃើញសោះ បើដោយស្មានទៅមិនលែងមានទេ ក្នុងក្បួនច្បាប់ចាស់ៗ ដែលចារនឹងស្លឹករឹត នៅស្រុកខ្មែរយើងនេះ ។ ឯពាក្យជំបូន្មានដែលខ្ញុំបាទនៅចាំបាន រហូតមកដល់សព្វថ្ងៃនេះដូច្នេះ :

(បទព្រហ្មគីតិ)

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

ក្សត្រាពឹងទសពិធ រាជបណ្ឌិតពឹងធម៌ស យោធាពឹងអស្សតរ
អ្នកគោចរពឹងសាលា ។ សំពៅពឹងព្រះពាយ អ្នកអភិប្រាយពឹងវាចា

ពជសីហ៍ពឹងគូហា សត្វមហិង្សាគោគពឹងស្នែង ។ ក្សត្រិស្រីរល័ក្ខណ៍

គពារកេរ្តិ៍យសស័ក្តិសែង ពឹងវត្តប្រតិបត្តិស្នែង ជាលំនៅទីប្រសើរ ។

. . . . . . . . . . . . . . . . . . . . . . . . . . .

## (បទកាកគតិ)

. . . . . . . . . . . . . . . . . . . . . . . . . . .

ធ្វើអ្វីឲ្យស្ងាត់ ធ្វើអ្វីឲ្យបាន ធ្វើអ្វីឲ្យផ្ចង់ ធ្វើអ្វីឲ្យត្រូវ ធ្វើអ្វីឲ្យត្រង់
ធ្វើអ្វីឲ្យគង់ ធ្វើអ្វីឲ្យគាប់ ។ រីធ្វើឲ្យស្ងាត់ បើអត់ក្រោធថ្កាន
រំលាយទោសធាប់ រីធ្វើឲ្យបាន បើឲ្យមានទ្រព្យ បើផ្ចង់ចិត្តស្តាប់
ច្បាប់ច្បាស់មាត្រា ។ រីធ្វើឲ្យត្រូវ បើគិតដោយនូវ ច្បាប់ក្បួន
សាស្ត្រា រីធ្វើឲ្យត្រង់ បើផ្ចង់ចិត្តជា កុំបីឆន្ទា មោហាគតិផង ។
រីធ្វើឲ្យគាប់ ឲ្យគង់សណ្តាប់ រៀនច្បាប់ក្រមផង បំណោរលង់ទៅ
ឋានបុណ្យពេកបោង ឲ្យអស់អ្នកផង រះរករៀនត្រាប់ ។ អ្វីគួរឲ្យផ្ចង់
អ្វីគួរឲ្យផ្គង អ្វីគួរឲ្យផ្គាប់ អ្វីគួរឲ្យត្រង អ្វីគួរឲ្យត្រាប់ អ្វីគួរឲ្យស្តាប់
អ្វីគួរឲ្យស្តាយ ។ គួរផ្ចង់សីលា គួរផ្គងគាថា គួរផ្គាប់ចិត្តនាយ គួរ
ត្រេកត្រង់ច្បាប់ គួរត្រាប់ប្រាជ្ញប្រាយ គួរស្តាប់បរិយាយ គួរស្តាយ
អាត្មា ។

. . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . .

ខ្ញុំបាទសូមជំរាបជូនដំណឹងដល់អស់លោក-អ្នកមើលទស្សនាវដ្ដីនេះ ប្រសិនបើលោកអ្នកឯណាមួយបានចេះចាំពាក្យកាព្យជាសុភាសិតបុរាណនេះចប់ចុងចប់ដើមក្ដី ឬមួយបានប្រទះឃើញនៅក្នុងច្បាប់សាស្ត្រអ្វីក្ដី សូមមេត្តាកត់ត្រាចម្លង ឬជូនដំណឹងទៅពុទ្ធសាសនបណ្ឌិត្យក៏បាន ដើម្បីឲ្យលោកចាត់ចែងបោះពុម្ពច្បាប់សុភាសិតដ៏ពិរោះនេះ ចុះផ្សាយក្នុងទស្សនាវដ្ដីកម្ពុជសុរិយា ជាប្រយោជន៍ដល់អ្នកមើលទាំងអស់គ្នា ។

នៅទីបំផុត ខ្ញុំបាទមានសង្ឃឹមថា ពាក្យដំបូន្មានបុរាណទាំងប៉ុន្មានបន្ទាត់ដែលបានពោលមកនេះ ល្មមជាគ្រឿងប្រដាប់សតិបញ្ញារបស់អស់លោក-អ្នកមើលបានខ្លះពុំខាន ទើបខ្ញុំបាទសរសេរសុភាសិតដែលខ្ញុំបាទចាំមាត់តាំងពីក្មេងមកនោះ យកមកជូនពុទ្ធសាសនបណ្ឌិត្យ ដើម្បីឲ្យលោកចុះផ្សាយក្នុងទស្សនាវដ្ដី កម្ពុជសុរិយា ជាប្រយោជន៍ដល់សាធារណជនទាំងឡាយតទៅ ។

# ឃុនឧត្ដមប្រីជា ជាប-ពិន

## រួបរួមនិងរៀបរៀង

(តមក)

| បណ្ដៅ | ដោះស្រាយ |
|---|---|
| ៣៨ - ដើមក់ជក់ទឹក ស្លឹកក់ជក់ខ្យល់ អ្នកផងស្ងួយឆ្ងល់ ដើមដុះឯណា ? . . . . . . . . . . . . . . . . | ចក |
| ៣៩ - ដើមប៉ុនដងជញ្ជីង ស្លឹកលើងផ្កាស ផ្លូវអើយផ្លូវបង ទៅរកផ្សិតដើមនោះក្រ ដុះតែដោយមាត់ស្បូវ ?. | រុន |
| ៤០ - ដើមក់រហូរ ស្លឹកក់កញ្ចាញ់ចូរ ផ្លែក់មូលប៉ែន ?. | ត្នោត |
| ៤១ - ដើមក់ប៉ុនស្គរទើត ក្រាប់ក់ប៉ុនក្រាប់ស្ពៃ ? . . . . | ដូង |
| ៤២ - ដើមក់កន្ទៃ ផ្កាទីងផ្លែនៅឆ្ងាយពីគ្នា ? . . . . . | ពោត |
| ៤៣ - ដើមក់ប៉ុនខ្សែពាន ស្លឹកក់យោនយាន ផ្លែក់ញ៉ុកញ៉ុច ? . . . . . . . . . . . . . . . . . . . | ម្រះ |
| ៤៤ - ដើមក់ប៉ុនកន្ទាស ស្លឹកក់រចិះរចះ ផ្លែក់រញេញរញុញ ?. | ម្រះ |
| ៤៥ - ដើមក់ប៉ុនទៀន លៀនឡើងប៉ុនស្លាក ផេកផោក កណ្ដុកលបង ? . . . . . . . . . . . . . . . . . | ឈូក |
| ៤៦ - ដើមក់ប៉ុនទៀន លៀនឡើងប៉ុនចាស ? . . . . . | ព្រលិត |

| បណ្តៅ | ដោះស្រាយ |
|---|---|
| ៤៧ – ដើមកន្ត្រៃ ផ្លែកន្តាន់កាន់ យកដៃទៅកាន់ កន្តិតម៉ែ ? . . . . . . . . . . . . . . . . . | ម្ទេស |
| ៤៨ – ដើមជាអង្គឯក មែកជាអង្គអើ ដីគោះដីគើ ដីអឺអឹកអាំ ? . . . . . . . . . . . . . . . . | ខ្សៀ |
| ៤៩ – ដើមកន្ត្រៃ ផ្លែប្រកស្រោម ? . . . . . . . . | ប៉េងប៉ោះស្រោម |
| ៥០ – ដើមក្រឡាក្រឡាញ់ ស្លឹកកន្ត្រាញ់ ផ្លែផ្សរចត់? | ទិត |
| ៥១ – ដើមប៉ុនសរសៃអម្រោះ ស្លឹកកម្លូលកំប៉ោះ ផ្កាកស? | ស្តន់ |
| ៥២ – ដើមពិសី នៅខ្ទំពិសា ដល់ខ្ទុំកាលណា គេ ចោលបង្រៀត ? . . . . . . . . . . . . . . . . | ឧតោង |
| ៥៣ – ដើមជាគ្រឿងទេស ផ្លែកពិសេសពិរោះល្អប់ អ្នកផងស្រឡាញ់គ្រប់ ពុំដែលស្អប់ទេអ្នកអើយ ? . . | ប័ន្តក្រស្នា |
| ៥៤ – របស់មួយមកពីស្រុកយួន គេបៀកបួនមាត់ប្រហ ? . | ពាង |
| ៥៥ – របស់មួយតូចគល់ធំចុង រុញចូលទៅក្នុង ធ្វើ ក្រៃគមមី ? . . . . . . . . . . . . . . . . . . | ជម្ប៉ារត្រចៀក |
| ៥៦ – របស់មួយមានស្លាបមិនចេះហើរ មានជើងមិនចេះដើរ មានមាត់មិនចេះស្តី ? . . . . . . . . . . . . . . . . | ផ្ទះ |

បញ្ហា ដោះស្រាយ

៥៧ – របស់មួយមាននៅស្រុកខ្មែរ – យួន មានបន្លា ផ្លែក
ស៊ីផ្អែម? . . . . . . . . . . . . . . . . . . ខ្នុរឬធូរេន

៥៨ – របស់មួយមាននៅស្រុកខ្មែរ – យួន មានភ្នែកជុំខ្លួន
ដើមដុះលើផ្លែ? . . . . . . . . . . . . . . . . ម្នាស់

៥៩ – របស់មួយនៅជិតបង្កើយ តែមើលឃើញឆ្ងាយ
លន្ទឹម? . . . . . . . . . . . . . . . . . . . ពុកច្រមុះ

៦០ – របស់មួយមានតែក ឥតក្បាល មានតែខ្លួន
ឥតជើង? . . . . . . . . . . . . . . . . . . . អាវ

៦១ – របស់មួយមានតែចង្កេះ និងជើង ឥតខ្លួន
ឥតក្បាល? . . . . . . . . . . . . . . . . . . ខោ

៦២ – របស់មួយមកពីស្រុកសៀម អង្គុយស្ងៀមៗ គេ
ចាប់ដាក់ខ្នោះ? . . . . . . . . . . . . . . . . ជើងក្រានសៀម

៦៣ – របស់មួយវែងមិនវែង ខ្លីមិនខ្លី ដាក់ជើងដល់ដី ធ្វើ
ភ្នែកស្រឡៅ? . . . . . . . . . . . . . . . . គ្រឿងស្ទង់

៦៤ – របស់មួយមកពីស្រុកជង យកដៃច្រពន់ៗពុំដែល
ញាស់ ច្រមុះនោះសើងស្រួចណាស់ ក៏តែងបន្ទស់
ជីវិតសត្វផង មានគូរដូចជាផ្លែង គូរនោះសោត

| បណ្តៅ | ដោះស្រាយ |
|---|---|
| ហោង ឥតមានគង្គា ត្បូងថ្ងៃនិត្យនៅហត្ថា មាន<br>ទងលកា វល្លិតែខ្ទដើមបុង ខ្ទួនក់នោះណា សឹងជ្រង<br>កន្ទុយសោតត្រង់ ឥតមានក្បាបក្បូរ មានឃុំទំនៅ<br>ក្បាលអ្នូរ ចំគ្គក់គិតគ្នូរ ចង់ខាំបក្ស ហិចហោះ<br>ផ្ទុកផ្ទោះឥតបី ស្បូរសព្វអសនី បីដូចរន្ទះដើមឆ្នាំ ? . . | ស្ពា |
| ៦៥ — មេត្រស កូនដេញ ? . . . . . . . . . . . . . | ស្ពា ឬខ្ទុ |
| ៦៦ — គល់ក់ជាក្មេងអ្នកដង, កណ្តាលជាគង, ចុងជាបក្សា? | ដើមត្រែងសេក |
| ៦៧ — ណៃលណោលកណ្តាលបាត ត្រែបនរនាទ<br>កណ្តាលបង់ ស្នែងប្រឡង់ផង់មិនមុត ? . . . | ខ្យង |
| ៦៨ — អ្នកឡើងមិនបានបេះ, អ្នកប្រឡេះមិនបានស៊ី, អ្នក<br>នៅទទេស៊ីផ្អែត ? . . . . . . . . . . . . . . . . . | ជើង ដៃ មាត់ |
| ៦៩ — មានភ្លើងមិនឆេះ មានផែះមិនហុយ ស្អុយមិនធុំ<br>ហើរមិនទំ យំមិនឃើញរូប ? . . . . . . . . . | ភ្នាតភ្លើង<br>ភ្នាតផែះ<br>ដើមអាចំកុក<br>ពពក ផ្គរ |

| បណ្តៅ | ដោះស្រាយ |
|---|---|
| ៧០ — មួយលោទ មួយដេញ មួយសើចសៀញ មួយលាវ | ដើមលោទ<br>ដើមរំដេញ<br>ដើមក្រូច<br>សើចឬម្រេច<br>ដើមល្វា |
| ៧១ — បន់ជំឲ្យបាក់ បន់កក់ឲ្យដាក់ បន់រែកឲ្យបាំង ?. . . | ស៊ីបាយ<br>ផ្ទិយបាយ<br>ដម្រិះស្មៅ |
| ៧២ — ឈើនាប់មានដង្ហើម សត្វឥតឆ្អឹងនៅក្នុងទឹក ស្ងួន ហើយមាសតាទូក , បណ្តូលមានទឹក ដើមដុះលើគោក? . . . . . . . . . . . . . . . . . . | ស្នប់<br>ឈ្នើង<br>បង្គង<br>អំពៅ |
| ៧៣ — ឈើមួយកំណាត់មានដង្ហើម សត្វឥតឆ្អឹងនៅកណ្តាលទន្លេ ចំងទឹងគេទះទ្រូងឯង ?. . . . . . | ស្នប់ បង្គង<br>ទះមូស |
| ៧៤ — មានខ្សែមិនចង, មានដំបងមិនកាន់ មានបន្ទូរមិនពិដោរ, មានត្រាវមិនស្ងោរ, មានវែកមិនដួស ? . . . . . . . . . . . . . . . . | ពស់ខ្សែគោ,<br>ពស់ដំបងត្រញូង,<br>ពស់បន្ទូរមេ, ពស់ផាងត្រាវ, ពស់វែក |

បណ្ដៅ ដោះស្រាយ

៧៥- គេះធ្នឹមជំនីរ, ស៊ីប្រហុស, អោបដីទះពោះ, ដឹក
សេះកាត់ត្រឡោក? . . . . . . . . . . . . តាប៉ុ / ប៉ុអ / ស្គរ / ទ្រ

៧៦- ដើមមួយទល់ដីស្នែងបិឯក្បាល ពោះវាប៉ោលប៉ោល
ដុះដោះខាងឆ្វេង មានផ្កាមួយ វាតែងបាញ់
លេង បាញ់ត្រូវខ្លួនឯង ស្រែកយំរាល់ព្រឹក? . . ទ្រ

៧៧- កូនក្មេងតូចមួយ លីស្នាទៀងក្នុ ត្រដៀវរ៉ុចយំ
កែវអើយស្រណាត់? . . . . . . . . . . . ទ្រ

៧៨- កូនស្ងួនពិសេស ខាមជាអ្នកទេស តម្ងន់បាន
ធ្លាយ គេរិតគេរួត គេដំគេវាយ ទាំងកូន ទាំង
ម្ដាយ ហាក់ដូចមានទោស? . . . . . . ស្គរដៃ

៧៩- ត្រឡាចមិនត្រឡាច ល្ពៅមិនល្ពៅ លើកដាក់
លើភ្លៅ កន្ទ្រឹមតាក់ស្ទ្រ? . . . . . . . ស្គរដៃ

៨០- ដើមវាស្លក់ មាត់វាស្ងួញ អាហារខ្លួចលាញ
ទាល់ហើយបណ្ដៅទៅ? . . . . . . . . ដើមទាល់

៨១- ទឹកមួយថុក ជ្រកដេកវណ្ណល? . . . . . . . ថ្នាងស្នោរ / អន្សមជ្រូក

បណ្តៅ ដោះស្រាយ

៨២- ចុកគោក, ដំបូកទឹក? . . . . . . . . . . . ផ្លែផ្ទឹង.ដោះស្រី

៨៣- កាប់មួយចុះដល់ថ្ម កាប់មួយចុះដល់ដីស

កាប់មួយចុះដល់ទឹកសមុទ្រ? . . . . . . . . ផ្លែផ្ទឹង

៨៤- ទឹកមួយថ្លុក ខ្យល់បក់មិនត្រូវ? . . . . . . . . ផ្លែផ្ទឹង

៨៥- ទឹកមួយថ្លុក ក្អែកមិនឃើញ? . . . . . . . . ផ្លែផ្ទឹង

៨៦- តិកតុកត្រពាំងដូនតា ទឹកមិនដែលថ្លា ស្មៅមិន

ដែលដុះ ក្អែកមិនដែលចុះ ត្រីមិនដែលមាន? . . ជ្រាំ

៨៧- អង្គុយមួយសន្ទុះ អាចម៍មួយច្រកាយ? . . . . . អាចម៍បន្ទោះ

៨៨- ក្រោកក្រៀន? . . . . . . . . . . . . . . . អាចម៍បន្ទោះ

៨៩- តុកតុលមមុលកន្ទង់ សក្តុជើងប្រាំបី នាំមុខតុកតុល? . ខ្គុល

៩០- ស៊ីទឹងចំពុះ ជុះទឹងស្មាប? . . . . . . . . . . ខ្គុល

៩១- ឈើកោងលែងឈើកាង ការក្បាច់ផាង ត្រី

ខ្ទាត់ខ្ទាយ? . . . . . . . . . . . . . . ក្បាល់កិនស្រូវ

៩២- ជាន់កន្ទុយស្រែកឆែក? . . . . . . . . . . . ក្បាល់ជាន់អង្ករ

៩៣- អ្នកដេកពីក្រោមនៅស្រណុក អ្នកជាន់ពីលើអន្ទុកៗ

ស្ទើរបាក់ខ្នងចង្កេះ? . . . . . . . . . . . . ក្បាល់ជាន់អង្ករ

បណ្ដាំ ដោះស្រាយ

៩៤- ឈើពុករុកឈើខ្ទីម ឈើពារទន្ទឹមប៉ាន់ចំអើត? . . ត្បាល់ជាន់អង្ករ

៩៥- កាយមាស់ មាន់ឆាប់ស្រែកនោង ? . . . . . . រទេះគោ-ក្របី

៩៦- កំប្រុកកំព្រា អង្គុយលើក្អួយផ្ដួចៗ ? . . . . . . ចាយពុះ

៩៧- បើកបង្អួចបង្ហើរមាន់ស ? . . . . . . . . . . . ស្ដោះទឹកមាត់

៩៨- អង្គុយមាត់ដំណើរបង្ហើរមាន់ស? . . . . . . . . ស្ដោះទឹកមាត់

៩៩- យប់ឡើងឈ្មោះគ្មាអែ ព្រឹកឡើងពក់រៃ ពកម្ពុង
ជំនរ ? . . . . . . . . . . . . . . . . . . លោកសង្ឃ

១០០ គេស្អប់ជាត់ គេអាណិតស្គម ? . . . . . . . . . ការុង

១០១- ទ្រស៊ីផ្អែតបង្កក ? . . . . . . . . . . . . . . ការុង

១០២- សអើយសសាញ់ សអត់ពីអញ គេពោកស៊ុតដៃ ? ការុង

១០៣- ក្របីខ្មៅស៊ីតែចុងៗ គោសត្រឡង់ស៊ីតែគល់ៗ ? . កន្ត្រៃ,កាំបិតកោរ

១០៤- ឈើគោងប្រហោងកណ្ដាល ស្ដេចមានកាល
ត្រូវការឈើគោង ? . . . . . . . . . . . . . កាំភ្លើង

១០៥- អាធំដេងគ្រេង លេងទឹកមិនល្អក់ អាតូចបក់ម៉ក់
លេងទឹកល្អក់រៃ ? . . . . . . . . . . . . . . ឈ្នក់,អង្រុត

១០៦- ឫស្សីមួយគុម្ព ជញ្ជាំកុងបឹង ? . . . . . . . . អង្រុត

១០៧- ទៅពីអាយដូចគេទង់ ដាក់គូទកង់ ដូចគេខំ ? . . . . ជុះ

(មានត)

កាំពូលកាំសត់

# លោកហាន់-យេង រៀបរៀង

(តទៅ)

បទទី ១៤

## កណ្តាលព្រៃស្ងាត់

ព្រះអាទិត្យផ្អៀងជ្រេទេរទៅហើយ ខ្យល់រំភើយៗមកគួរឲ្យត្រជាក់ចិត្តនាកណ្តាលព្រៃស្ងាត់ មានសត្វស្វាលោតពីមែកមួយទៅមែកមួយ ចួនប្រើដៃ ចួនប្រើជើង ចួនប្រើកន្ទុយយោលតោងលេងតាមចំនើងចិត្ត ខ្លះបេះបោចផលាផលគេស៊ីផ្លែក្រមេចក្រមើមគួរឲ្យចង់សើច ស៊ីអស់ហើយនៅសល់គ្រាប់ក៏បោលទៅលើសុកិន្ទ្រ (ដែលកំពុងដេកលក់ឲ្យភ្ញាក់ឡើង) មុខស្រមេងស្រមើងគន់មើលចងពានរ ដែលខាំគ្នាឈរឡេកមុខផ្ដើនឲ្យ មានកូនតូចៗតោងពោះមេជាប់ សុកិន្ទ្រក៏ទឹកទោបក្នុងចិត្ត ដោយខ្លួនក៏ព្រាត់ម្នាក់ឯង កណ្តៃងកណ្តាបកណ្តាលព្រៃពុំដឹងទិសតំបន់ឯណា ធ្វើម្ដេចទឹងបានចួបមាតាអេះ សមជាអ្នកទទឹងមើលផ្លូវកូនយ៉ាងណាទៅ តើជម្ងឺអ្នកជាធ្ងន់ឬស្រាល ឱបងពានរ! អ្នកនៅជួបជុំគ្នាគួរឲ្យសប្បាយចិត្តអីម្ល៉េះ . . . ។

"ជួយផង! ជួយផង! ឮស្នូរសំឡេងមនុស្សរំពងឡើងកណ្ដាលព្រៃស្មសាន សុកិន្ទ្រក៏ងើបឡើងផ្ទៀងត្រចៀកស្ដាប់ តើសំឡេងមក

ពីទិសណា ដល់សំឡេងដែលលាន់សាជាថ្មីទៀត ក៏ស្ទុះរត់ទៅលុះ-ដល់មាត់ទន្លេ ទើបឃើញក្រមុំតាមម្នាក់ ត្រូវពស់ថ្លាន់រឹតជាប់នឹងដើមឈើ កំពុងតែរើបម្រះឲ្យឃ្លាតឆ្ងាយពីអាសិរពិស សុកិន្ទ្រឃើញដូច្នោះក៏កាន់ដំបងមួយស្ទុះទៅ ចំណែកពស់ឃើញមនុស្សមកជិតក៏រេក្បាលចុះឡើងក្រួចរឹតនារីបវរនោះ សុកិន្ទ្រក៏វាយឲ្យត្រូវក្បាលពស់អស់ទំហឹងដៃ ពស់គេចទាន់ អ្នកក៏ភ្លាត់ស្មៀតដួលប្រដាង សត្វសាហាវខឹងណាស់ មានភ្នែកទាំងគូដាលក្រហមរុងរោចន៍ដូចភ្លើងប្រល័យកល្បលាភ្នែនលែងរឹតអាហារក់ ស្ទុះមកប្រយុទ្ធនឹងប្រុសកំឡោះ យកកន្ទុយរ័ណ្ណជើងសុកិន្ទ្រជាប់លើកខ្លួនពីដីចំនួនមួយម៉ែត្រ ប្រាថ្នានឹងបោកទៅលើប្របពី ឲ្យខ្ទេចខ្ទីឆ្អឹងឆ្អែងល្អិតទៅជាផេះ សុកិន្ទ្រទឹកការនោជាប់ យារដំបងទាន់សំពងត្រូវក្បាលពស់យ៉ាងដំណំផ្ងប់ទៅនឹងដើមឈើ ពស់ក៏នីងើលាកន្ទុយក្រាកធ្លាក់ទាំងពីរនាក់ដល់ដី មនុស្សឥតប្រណីសំពងផ្ទួនថែមទៀត ត្រាតែដាច់ខ្យល់ផុតមរណភាពនាគ្រានោះឯង ។

ចំណែកនាងតាម មានសេចក្តីត្រេកអរក្រៃឆ្លៀបផងពុំបាន រៀបហោសសំអាតខ្លួនប្រាណដៃជើងស្អាតបាត យកក្រមារុំមុខដូចដើមវិញទុនយកកន្ត្រែងពោរពេសទៅដោយផ្លែឈើដ៏មានទុជារស រួចឈរអៀមអៀមមើលមុខសុកិន្ទ្រ សុកិន្ទ្រក៏សាកសួរដំណើរថា " ចុះអ្នកអញ្ចើញទៅណាមកណា បានជាមកត្រូវពស់វ័ណ្ណកណ្តាលព្រៃដូច្នេះ ? ។

"ចា៎ះ! ខ្ញុំមករកបេះផ្លែឈើយកទៅឲ្យបងប្អូនអាស្រ័យ ព្រោះនាំគ្នាធ្វើដំណួញដល់លក់ដូរអស់គិតវិលទៅស្រុកវិញ មកដល់ទីនេះចួនជាល្ងាច ទើបនាំគ្នាឈប់សំរាកទទួលទានបាយ ហើយខ្ញុំត្រូវប្រើឲ្យមករកបេះផ្លែឈើ ក្រៅអំពីនោះមកដូច . . . ដូច . . . បងជ្រាបស្រាប់សព្វគ្រប់ហើយ ការដែលបងបានជួយសង្គ្រោះជីវិតខ្ញុំនោះ ជាព្រះគុណធ្ងន់ណាស់ ខ្ញុំនឹងមិនភ្លេចទេដល់អស់មួយជីវិតរបស់ខ្ញុំ បងអាណិតអញ្ជើញទៅជាមួយនឹងខ្ញុំ ទៅឯទូកឯណោះ នឹងបានអាពុកម្ដាយខ្ញុំសងគុណអ្នកបងឲ្យគាប់ចិត្ត" ។

ថាហើយនាងក៏នាំមុខដើរទៅ សុកិន្ទ្រក៏ដើរតាមក្រោយ គន់មើលនាងបង់ហោយល្អសល្វន់ទន់ទាំងខ្លួន មួយស្របក់ក៏បានដល់ទៅទូក នារីមានរូបចុះទៅទូកទុកសុកិន្ទ្រឲ្យនៅពេលើច្រាំង មួយសន្ទុះមានតាមដួតក្បាលក្រមាស ពុកមាត់ស្កូវមុខញញឹមបញ្ចេញមកហាហៅកំឡោះនោះ "នែអ្នកកំឡោះ អញ្ជើញមកណេះនឹងបានប្រស្រ័យគ្នា ដល់សុកិន្ទ្រអង្គុយសិចស្រួលបួលហើយ គាត់ក៏និយាយពាក្យអរគុណជាច្រើន រួចបានសួរអំពីដំណើរដើមទងកុមារវិញ កាលបើសុកិន្ទ្រនិយាយប្រវត្តិរូបរបស់ខ្លួនចប់បរិបូណ៌ហើយ អ្នកស្ដាប់ទាំងប៉ុន្មានក៏ស្រក់ទឹកភ្នែកទឹកអាណិតគ្រប់គ្នា នៅស្ងៀមស្ងាត់អស់មួយស្របក់ធំ តាតាមនិយាយឡើងថា "ណ្ហើយកូន! អ្នកកុំកើតទុក្ខអ្វី មករនៅនឹងយើងមក

យើងនឹងចិញ្ចឹមអ្នក ព្រោះឪពុកក៏គ្មានកូនប្រុសដែរ ឪពុកសូមឯងជាកូន តើឯងសុខចិត្តទេ ?

“បាទ! ខ្ញុំបាទមានកិច្ចទៅរកមាតាផង នឹងនៅជាមួយលោកតា ដូចម្ដេចបាន” ។

“មិនអីទេ ចាំតាជូនឯងទៅរក កុំបារម្ភអ្វី ឲ្យតែសុខចិត្តព្រមធ្វើកូនតាចុះ” ។

សុកិន្ទ្រនឹកអស់អែកកន្ទុកចិត្ត មិនដឹងជានឹងឆ្លើយបែបណា ពេលភ្នែកមើលទៅឃើញនារីចាម កំពុងមូរក្រមានឹងម្រាមដៃ មានទឹកមុខមិនស្រស់បស់ មានភ្នែកទាំងគូអង្វរអ្នកឲ្យនៅ ទើបសុកិន្ទ្រព្រមព្រៀងនៅជាមួយនឹងត្រកូលចាមនោះ ។

លុះបរិភោគអាហារល្ងាចរួចហើយ សុកិន្ទ្រក៏ឡើងទៅលើប្រាំងដើរលេងក្រោមពន្លឺព្រះចន្ទ្រ ដើម្បីនឹងរំហើយខ្លួន មុននឹងចូលដំណេក ដល់កន្លែងមួយមានគល់ឈើស្អាត ក៏អង្គុយលេងនៅទីនោះ ងើយមុខមៀងមើលតារាករ ដែលរីកពយភ្លឺលន្វឹមឯនកាល័យ ទើបនឹកសម័យដល់មាតារបស់ខ្លួន បង្កើតជារូបនិម្មិតច្បាស់នឹងមំសចក្ខុ ឃើញរូបអ្នកស្គមរីងរៃកំរើកដៃជើងពុំរួច ញញឹមព្រៀមក្រស់មករក ហើយមានវាចាថា “ឱកូនកសម្ដាយអើយ! ម្ដាយនឹងដាច់ខ្យល់ស្លាប់ក្នុងវេលានេះ មិនខានទេ ម្ដេចឡើយមាសមេនាងមិនមករកម្ដាយ ឲ្យម្ដាយរង់ចាំដូច្នេះ

ឱកូនអើយ ! បើប្រសិនណាជាបានកូនមកជិត មុខជាម្ដាយនឹងជាវិញជាពុំខាន បើទុកជាស្លាប់សោតក៏ចង់ក្អែកជិតដែរ មករកម្ដាយណាណាកូនណា ” ។

សុភទ្រក៏ហុចដៃទាំងពីរទៅ រូបនិម្មិតក៏បាត់សូន្យមួយរំពេចនាំឲ្យកុមារគេចរកមើលពុំឃើញ នឹកចុកណែនខ្ពាទាន់តឹងស្មើរនឹងក្ខាយ ទឹកភ្នែកហូរធ្លាយមកពេញមុខ រួចក៏ដួលផ្ងប់ទៅលើព្រះធរណីដីនឹងខ្លួន ថាហាក់ដូចជាគេលើទៅឆ្ងាយទៅ រួចក៏ផ្អែកទៅនឹងដើមឈើយកអ៊ុំមកពទ្ធពទ្ធខ្លួនជុំវិញ ដល់បើកភ្នែកឡើងកំរើកដៃ ស្រាប់តែឈឺនៀបអស់សរសៃផ្សាពេញខ្លួន សំឡឹងមើលឲ្យជាក់ ក៏ឃើញចំណងយ៉ាងមាំ នឹកឆ្ងល់ណាស់ បែរមើលទូទាំងបរិវេណ ក៏ឃើញមនុស្សជាច្រើនអង្គុយនិយាយគ្នា សុទ្ធតែមានអាវុធគ្រប់ដៃ ទើបកុមារត្រាស់សួរគេថា “ លោកពូអើយ ! ហេតុដូចម្ដេចបានជាខ្លួនខ្ញុំត្រូវគេចងដូច្នេះ ? លោកពូជួយស្រោចស្រង់ខ្ញុំបានផង ” ។

ឈប់ប៉ុណ្ណឹងហើយ កុំនិយាយអ្វីតទៅទៀត តែខំមុខជាមានគ្រោះដល់ខ្លួនមិនខាន ។

រួចពួកអស់នោះនិយាយគ្នាតទៅទៀត អ្នកមួយនិយាយឡើងថា “ តាមខ្ញុំ កុំឲ្យពួកវាមកតាមអីនាំឲ្យពិបាកតយុទ្ធទេ យើងនាំគ្នាពួនឲ្យវាទៅផុតទៅ នឹងអាលវិលត្រឡប់ទៅប្ដូរទូកវាយកសម្បត្តិតែម្ដង ” ។

អ្នកមួយឆ្លើយថា "អេ ! យើងត្រូវទៅប្ដូនកុម៉ិងលិចឯណោះ ណ្ហើយលែងគ្នាទៅ កុំធ្វើបាបវាអី ព្រោះទុះជាសម្លាប់វាទៅក៏ពុំបាន ជាអ្វី" ។

អ្នកមួយទៀតបែកគំនិតថ្មីថា "បើដូច្នោះ យើងទុកម្នាក់ឲ្យយក សំបុត្រទៅកំហែងទារប្រាក់ចំនួន ២០០រ,០០ សុំមេបើកលែងក្មេងនេះឲ្យ ហើយពួកយើងនាំគ្នាទៅប្ដូនកុម៉ងលិច" ។

គិតព្រមព្រៀងដូច្នោះហើយ ក៏នាំគ្នាទៅចាត់អស់ទៅ នៅសល់តែម្នាក់កាន់សំបុត្រយកទៅប្ដុំក្នុងទូក រួចវិលមកវិញយាមល្បាតមនុស្សទោស ។

ដល់ពួកចាប់នោះឡោមើលសំបុត្រហើយមិនដឹងជាថាអ្វី ព្រោះអ្នកអស់នោះមិនចេះអក្សរខ្មែរ ទើបសួរគ្នាទៅវិញទៅមក ចួននៅនោះមានខ្មែរជាតិម្នាក់ ជួយមើលសំបុត្រឲ្យស្ដាប់ លុះដឹងរឿងហេតុហើយក៏តក់ស្លុតរឿងខ្លួន គិតនាំគ្នាតាមទៅ តែមកគិតគ្នាថាចាំព្រឹកចាំយើងនាំគ្នាទៅដណ្ដើមយក រួចក៏នាំគ្នាចូលដេកទៅ ទុកម្នាក់ឲ្យនៅមើលគយឃ្លាំ ។

ចំណែកនារីតាមឮដូច្នោះ នាងក៏ព្រួយចិត្តឡើងមកលើគោកដើរតាមស្នាមជើងមនុស្ស ស្មានថាអ្នកមានឧបការគុណលើរូបនាងប្ដេជ្ញាក្នុងចិត្តថា កាលបើខ្លួនអញរកអ្នកនោះមិនឃើញដកបណាអញក៏មិន

វិលមកវិញ ។ កបនោះ ចំរើមួយសន្ទុះទៅក៏បានឮស្នូរសំឡេងខ្សឹកខ្សួល មកប៉ះដល់ត្រចៀកនាង នាងក៏ភ្ញាក់ព្រើតងើបតិចៗ សន្សឹមៗ ចូលទៅ ឃើញចោរដេកលក់ស្រមុកខ្ទរៗ ឆ្ងាយពីនោះបន្តិចឃើញសុភ័ទ្រកំពុង រមៀលខ្លួន ទើបនាងនឹកអាណិតខ្លោចចិត្តក៏សុះចូលទៅស្រាយចំណង នៅសល់តែមួយជុំទៀតនឹងផុតស្រឡះ ស្រាប់តែឃើញមនុស្សខ្ទុកក្ដិត ភ្ញាក់ឡើងភាន់ នាងក៏ធ្វើជាដើរចេញមកក្រៅ ប្រឹងកម្រះញញឹមញញែម ចោរក៏និយាយដោយពាក្យទន់ថា “ ឱនាងទេព្ធអើ! ខ្ញុំស្មានថាជាអ្នកណា នាងទៅណាមកណាក្បែរ ចាំខ្លួនខ្ញុំបានទេ ?

“ចា៎ះ! ខ្ញុំស្គាល់អ្នកបងច្បាស់ ខ្លួនខ្ញុំនេះអផ្សុកដើររំហើយខ្លួនឃើញ អ្នកបងបានជាដើរចូលមកជិត តែឃើញដេកលក់ពុំហ៊ានហៅ ” ។

នាយចោរនោះ ភ្ញាប់ផាប់ចិត្តស្នេហានឹងនាងនោះ ក៏និយាយ ផ្អោះផ្អងទៅមកជាច្រើន នៅពេលនោះ ស្រាប់តែឮស្នូរជើងដើរពី ក្រោយខ្នង នាងធ្វើជាភ័យហើយខ្សឹបប្រាប់នាយចោរនោះថា “ អ្នកបងអើយ ឪពុកខ្ញុំមកតាមខ្ញុំហើយ តែគាត់ឃើញខ្ញុំអង្គុយលេងជាមួយនឹងអ្នកបង មុខជាគាត់វាយខ្នងខ្ញុំជាមិនខាន អ្នកបងអាណិតជួនទៅសិនទៅ ” ។ នាងក៏ក្រឡេកឃើញពួកគេនៅទៀបនោះ ក៏បង្ហំឲ្យនាយចោរត្បូលចូល គងពួកគេនោះ លុះដោយៈសេចក្ដីស្រឡាញ់គ្របសង្កត់ ចោរនោះក៏ព្រម

ចូល ផុតដើរហើយនាងក៏រកខ្សែបង់មាត់យ៉ាងខ្ជាប់ រួចគេចចេញមក នាំសុកិន្ទ្រតែវិលទៅទូកវិញ ។

កំឡោះនឹងក្រមុំទាំងពីរនាក់នោះ នាំគ្នាត្រសងមកវិញយ៉ាងលឿន. មានចិត្តរីករាយសប្បាយចិត្ត ងើយមើលនក្ខត្តឫក្សហើយដកដង្ហើមយ៉ាងវែងដោយសេចក្តីរំដោះទុក្ខ នារីតាមបើកមុខឡើងឲ្យច្បាស់ គន់មើលឃើញត្រចះត្រចង់មូលក្រឡង់ដូចគេគូរ ភ្នែកទាំងពីរព្រាយពន្លឺប៉ិតដូចផ្កាយលើមេឃ មណ្ឌលមុខពេញគរ័ផូរផង់ប្រមុះស្រួចត្រង់សណ្ឋានប្រ-មុះបាក់ង នាងមានរូបឆោមលោមព័ណ៌គួរឲ្យត្រេកត្រអាលឲ្យរ័ក្តកាំងស្មារតី វិស័យដូចទង់កាមទេពប្រាកដ ដំណើរនាងទ្រង់ស្រគត់ស្រគំរៀបរយល្អណាស់ បង់ចោយយាងយាសសមសួនទឹកពងក្លៅតូចទ្រនាប់ សុកិន្ទ្រគន់មើលសព្វហើយក៏បានដល់ទូក ។

ពួកពាមផ្អើលឡើងសាកសួរដំណឹង រួចគិតជុំគ្នានឹងធ្វើម្ដេចឲ្យផុតពីចោរទ្ទកយនោះ ទើបព្រមព្រៀងគ្នាថានឹងចេញទៅទាំងយប់ទើបបាន ដាច់ស្រេចហើយក៏ទាញយុថ្កាស្រាវត្រួរចេញទូកចាកទីនោះទៅ ចំប្រញាប់ដៃចែវមិនហ៊ានឈប់បង្អង់ ចំផ្ទង់ស្មារតីមិនឲ្យងងុយដោកងក់ លុះទៀបភ្លឺព្រឹមានរភើរសាទតាមខ្យល់មកក៏បានដល់ភូមិគេ ដូចចិត្តទាំងគ្នាសម្រាកខ្លួននៅទីនោះ នារីហមក៏លើកបបរត្រីងៀតយកមកលៀងអ្នកហត់នឿយ ។

# បទទី ១៥

## ម៉ាសអើយនាងម៉ាស

ព្រះសុរិយទេវបុត្រស្ដេចចេញពាកទិព្រា ខ្ទង់ឡើងប្រថាប់លើព្រះពសុធ គោចរតាមវិថីសត្វកាលសព្វគ្រា បើកខ្លោងទ្វារប្រាសាទស្ដេចចេញមកញញឹមព្រាយ មានព្រះភក្ត្រកាយស្រស់បស់មានអធ្យាស្រ័យទន់ភ្លន់ ពេលនេះត្រាយ៉ាំងស្រទន់មកលើភូមិប្រាំងចំពោះបក្សីឲ្យឃើញសំណាញ់លាតលាក្រែងនៅមុខផ្ទះ ជាឧបករណ៍សំ-គាល់នៃភូមិអ្នកនេសាទត្រី មានពន្លឺឆ្លុះចាំងចូលទៅក្នុងបន្ទប់នៃផ្ទះការផ្សាលគ្រឿងមួយ ញ៉ាំងបន្ទប់តូចនោះឲ្យភ្លឺឡើង ។

ក្នុងបន្ទប់នោះ នាងម៉ាសកូនតាឡាយម៉ាណ កំពុងឈរកញ្ចក់គន់មើលរូបកាយរបស់នាង នាងបានរើក្រមាពណ៌គ្រប់បែបពីទូចេញមកហើយយកមកទល់ម្ដងមួយៗមើលតើពណ៌បែបណាសមនឹងរូបនាង រើសចុះរើសឡើងក៏នៅតែទាស់ចិត្ត ព្រោះឆ្នូតផ្កាមិនសូវស្រស់ ឬផ្កាមិនសូវល្អ រើសរបៀបជាច្រើនលើកច្រើនសារ ជួនទម្លាក់មកលើស្មា ជួនឲ្យខ្ពស់ឡើង ជួនឲ្យវែងចុះ ពុំនោះសោតខុសពីសក់ចេញក្រៅសំពត់ ក៏ខំពត់ចុះពត់ឡើងដោយយកចិត្តទុកដាក់មិនមែនត្រឹមមួយពីរនាទីប៉ុណ្ណោះទេ ដែលនាងតាក់តែងកាយ គឺនាងក្រោកឡើងតាំងពីព្រលឹមឯណោះ ឈរតែសំឡឹងកញ្ចក់ចុះមុខ យូរៗ ញញឹមរករូបរបស់នាងម្ដងៗ ធ្វើឫកផ្អៀងផ្អងដូចនាងកិន្នរី គួរឲ្យមានចិត្តមេត្រីនឹងរូបនោះមកពេកនាងក្រៃលែង ។

តែដោយហេតុអ្វីហ្នឹង! បានជានាងយកចិត្តទុកដាក់ទីងសំអាងខ្លួនខុសពីថ្ងៃមុនៗ? ជាបញ្ហាដែលនាងបានសាកសួរដល់ខ្លួននាងកប់រយដងមកហើយ តែនាងរកអោយចក្ខុដោះសាពុំឃើញ ពុំដឹងជាដោយអានុភាពកំបាំងអ្វីនាំឲ្យនាងអណ្តែតអណ្តូងកយមាយថ្ងៃបេះ ហេតុការណ៍ដែលមានមកដល់ជីវិតរបស់នាងថ្មីៗ នោះ គឺសុភិទ្រូបានចូលមកជ្រែកក្នុងត្រកូលរបស់នាងនោះឯង ហើយមានឋានៈជាបងចិញ្ចឹមរបស់នាងផង ក្នុងចំនួន ៤ ខែទៀតទីងឡើងជាបងរបស់នាងបង្កើតតាមច្បាប់ កាលបើគុណារនេះ ចូលជាតិតាមចុះឈ្មោះជាបុត្រឡាយម៉ាណាពេលណាៗ តែអ្នកស្រុកគេហៅថាឧតៗ ត្រប់គ្នា កាលបើនាងម៉ាសរំពឹងគិតដល់រឿងនេះ ក៏ទឹកសើបតែម្នាក់ឯងលែងខ្ទះកញ្ចក់ បេញទៅឈរនៅមាត់បង្អួចរំពៃមើលធម្មជាតិនានា នាពេលនោះធម្មជាតិព្រឹកព្រលគារល្ងឹកថ្ងៃដល់ក្ដែករបស់នាង ហាក់ដូចជាមានវិញ្ញាណចេះនិយាយសាសងមករក បេះផ្សំបោតុឲ្យស្រមតាមរឿងតាមទឹកចិត្តរបស់នាង បក្សាបក្សីព្រៀងត្រលួចមកប៉ះត្រចៀកនាងហើយ សមខ្យល់រំភើយៗ មកទៀត ធ្វើឲ្យនាងព្រឺចព្រឺញាប់ញ័រដល់ខ្យែកវង្ក ដែលកន្ទិញរងឹ ទៀងក្នុងខ្លួនរបស់នាងហាក់ដូចជាមានខ្សែសម្ពន្ធអ្វីមួយ រួបចិត្តរបស់នាងទៅទីងធម្មជាតិ ៗ ដើមអំពិលមែកសាខាមានផ្កាយោងរយាន ដើមមកឿខៀវស្រងាត់ស្រួចត្រដឹមទៅលើ សំណាញ់ខ្មៅដែលទំរេក

លើបន្តិចឬស្សី  ស្ពានឈើដុះស្លែចុះទៅក្នុងទឹក  ទាំងនេះជាទីលើករបស់នាងដល់ទៅអនាគតជាប្រារម្មណ៍មិនទ្រុឌទ្រោមដល់សតិរបស់នាងគឺកៀនសមាគមរបស់នាងរៀងទៅ  ជាសការទិត្យនៅតែមួយកន្លែងមិនទិកសទៅទីណា ដែលញ៉ាំងទឹកភ្នែកឲ្យហូរប្រោកមកបាន  ឬមួយធ្វើបបូរមាត់ឲ្យញញឹមផ្អែមល្ហែមតាមពេលតាមកាលដែលចិត្តនឹងត្រេកអរសោទរឬស្រពោនស្រពន់សោកសូន្យ ។

“ម៉ាសអើយ! សំឡេងយាយឆ្នាំស្រែកហៅពីផ្ទះធំមក ។

នាងម៉ាសក៏ភ្ញាក់ព្រើតចេញចាកការសម័យ  ស្ទុះចេញទៅជាយ៉ាងប្រញាប់ប្រញាល់  ដើម្បីនឹងទទួលពាក្យបង្គាប់របស់មាតា ។

“ម៉ាក់! ត្រូវការប្រើកូនឲ្យធ្វើអ្វី?

“ឯងយកទឹកតែទៅជូនឪពុកឯង  នឹងបងឯងផង” ។

នាងទទួលពាក្យហើយ  យកដៃទទួលប៉ាន់តែយាងយាសដើរដំរង់ទៅកន្លែងធ្វើការ  លុះដល់កាលណានាងក៏ឱនចុះយកពែងមកសិតទឹកតែដាក់លើចានរង  រួចទើបនាងលើកយកទៅជូនឪពុករបស់នាង តពីនោះមក  បានទៀងយកទៅហុចឲ្យសុកិន្ទប្អូនទៅឧត  កាលបើនាងមើលមុខគេចំហើយ  មុខនាងក៏ឡើងក្រហមព្រឿងៗ ដៃរបស់នាងក៏ញ័របន្តិចធ្វើឲ្យធ្លាក់ទឹកក្ដៅទៅលើដៃកុមារ  ដែលទទួលពែងពីដៃនាង  ហើយនិយាយដោយស្មោះថា  “អរគុណហើយអូន  បាទអូនសិតទឹកតែឲ្យមុខជាខឹង

មានកំឡាំងព្រឹសមិនខាន អូនបងថ្ងៃនេះល្អចំណាប់ណាស់ សមខ្លួន ផាត់ក្រមាទៅខាងក្រោយផង បងនឹកស្មានថាជានាងទេពអប្សរចុះមក លេងផែនដីទេតើ បងមិនបញ្ញាអូនទេកុំឲ្យអៀនអន់ធ្ងើអ្វី ព្រោះថ្ងៃនេះ អូនប្លែកជាងសព្វកាលច្រើនណាស់" ។

នាងម៉ាសក៏ញញឹមយ៉ាងស្រស់ ទទួលពាក្យសរសើរដល់លំអរបស់នាង ពេញចិត្តនឹងសំដីដ៏ពីរោះជាប់ចិត្តនោះពន់ប្រមាណ ទឹកអរព្រួចក្នុងពោះស្រាលអស់ខ្លួនប្រាណអណ្ដែតអណ្ដូងជាសុខ មានទឹកមុខរីករាយសប្បាយឥតគណនា កើតបីតិព្រាងព្រាយថ្លាស្រឡះច្បាស់ដល់ចិត្តរបស់នាង ទឹកចង់អង្គុយនៅទីនោះឲ្យយូរបន្តិចទៅទៀត ដើម្បីនឹងគន់មើលឧតដួសសំណាញ់ផ្កាយ តែដោយទីនោះវាលស្រឡះពេក នឹងត្រូវអ្នកដទៃគេឡេកមើលគប់គ្នា ទើបនាងម្ចាស់វិលចូលទៅក្នុងផ្ទះវិញ ដើរទៅហាក់ដូចជាមានអ្វីស័ក្ដិសិទ្ធិទ្រទ្រង់ ស្រាលដូចសំឡីឈានជើងដើរស្ទើរមិនជាប់នឹងផែនដី ព្រោះតែប្រឹមប្រិយរករបស់ស្និទ្ធស្នាលនៅជិតភ្នែក មុននឹងឡើងទៅលើ នាងក៏ឆោលភ្នែកក្រឡេកមើលទៅចៅឧត ក្នុងពេលនោះហាក់ដូចជាភ្ញាក់ដោយបុទ្ធិមេផែត ក្រឡេមករក ក៏ប្រទះភ្នែកទឹងភ្នែកនាំឲ្យនាងមានសេចក្ដីត្រេកអរជាច្រើន ។

យប់នោះ នាងអង្គុយលេងជិតបង្អួចមៀងមើលមេឃ នៅកណ្ដាលពពួកផ្កាយជាបរិវារ ព្រះចន្ទ្រាមូលក្រឡង់ស្រស់បំព្រងផ្សព្វផ្សាយពន្លឺ

ពាសពេញ ញុំាងផ្កាំងព្រឹក្សាឲ្យស្រស់ញញឹមព្រោងព្រាយ នាំឲ្យមនុស្សរីករាយសោយទុក្ខពីថ្ងៃ ឯសត្វរៃយំរ៉ៃ ៗ ឥតអាក់ក្រោមស្លឹកឈើ សត្វប្រជៀវហើរឆ្វៀលឆ្វាត់ឯវេហាស៍ ខ្យល់រំភើយ ៗ មកត្រូវនាង ធ្វើឲ្យនាងព្រឺព្រួចទាំងសព៌ាង្គកាយ មានចិត្តសប្បាយនៅគន់មើលនក្ខត្តឫក្សតទៅទៀតតែឯកឯង ដល់យប់ជ្រៅបានជាចិត្តក្រោកចាកទីនោះចូលកាន់ដំណេក តែនាងមិនបានធ្មេចភ្នែកតែម្តងទេ នៅសញ្ជឹងហេតុការណ៍ផ្សេង ៗ ចុងបំផុតក៏លើកដៃធ្វើសញ្ញាលាយ៉ាងទន់ភ្លន់ញញឹមព្រាយហើយបានបិទភ្នែកជាសុខទៅ តើនាងលាអ្នកណាហ្ន៎មុននឹងនិទ្រា ? ប្រហែលជាលាព្រះចន្ទហើយមើលទៅ ៗ

ចំណែកខាងចៅឧត ក៏អង្គុយគន់ធម្មជាតិស្រស់បំព្រងដែរ គន់មើលខែមើលផ្កាយលើមេឃ តាមមើលដំណើរពពកដែលសាត់មកពីទិសទក្សិណសន្សឹម ៗ មកបិទម្តង ៗ ទាល់តែដល់ព្រះចន្ទហើយបាំងមិនឲ្យពណ្ណរាយ ភូមិឋានងងឹតបុះកក្រ្តា នាយឧតក៏ស្រងូតស្រងាត់សៅហ្មង កុមារហាក់ដូចជាសាបសូន្យក្នុងចិត្តស្រណេះស្រណោចកណ្តោងកណ្តោចពន់ពេកណាស់ ដល់ព្រះចន្ទភ្លឺច្បាស់ឡើងវិញ ក៏បានឮស្នូរតាមខ្យល់បក់មក កាត់សេចក្តីស្ងាត់នៃរាត្រីកាល នូវសំឡេងមាតាបំពេបុត្រយ៉ាងលន្លង់លន្លោចគួរបេងយំ នាយឧតកើតទុក្ខប៉ុនភ្នំ ដកដង្ហើមធំជាច្រើនដង នឹកដល់មាតារបស់ខ្លួនដែលមានជម្ងឺឈឺជាទម្ងន់ សមភ្នែក

*អ្នកខាន់ផង    ទឹកភ្នែកស្រក់ចុះមកជោកថ្ពាល់ទាំងគូខ្សឹកខ្សួលជាច្រើន ហើយមើលពពកសដូចស្បៃដណ្តប់មេឃ   សាត់វិលទៅទិសទក្សិណវិញ អ្នកក៏ស្រែកផ្តាំថា :*

"ឱពពកអើយ ! អ្នកអាណិតឈប់បង្អង់មួយស្របក់សិន ចាំស្តាប់ពាក្យបណ្តាំរបស់ខ្ញុំ   អ្នកតែងសាត់វិលវល់ឯអាកាស គង់ស្គាល់ទីលំនៅនៃមាតារបស់មាតាខ្ញុំជាមិនខាន  បើអ្នកទៅដល់ទីក្រុងភ្នំពេញហើយ   អ្នកមេត្តារកមាតាឲ្យខ្ញុំផង  ហើយជំរាបថា     ខ្ញុំនេះមានសេចក្តីនឹករលឹកមកដល់អ្នករាល់ទិវារាត្រី   មានចិត្តស្រពោនស្រពន់ស្ញប់ស្ញាត់ពុំរីករាយ   តែហេតុដែលយឺតយូរពុំបានទៅជួបនោះ   ព្រោះជាប់នៅតបស្នងសងគុណាត្រកូលទ្បាយម៉ាននេះ    ដែលបានជួយជីវិតរបស់ខ្ញុំ  នឹងបានជួយឧបត្ថម្ភឲ្យបានសុខមានជីវិតរស់នៅតាមធម្មតា តែថាក្នុងមិនយូរប៉ុន្មានទេ    ខ្ញុំនឹងទៅជួបមុខអ្នកមាតាជាមិនខាន  ពាក្យបណ្តាំរបស់ខ្ញុំអស់ប៉ុណ្ណោះហើយ  ពពកអើយ ! អ្នកកុំភ្លេចឲ្យសោះណាពពកណា !!!     (មានត)

ច្បាប់ក្រមបរិយាយ

# លោកញឹក-នូ គ្រូបង្រៀនជំនួយ

នៅវិទ្យាល័យស៊ីសុវត្ថិ រៀបរៀង

(តមកនឹងចប់)

គ្រូបាធ្យាយ បានជាលោកប្រៀបដូចមាតាបិតានោះ ព្រោះលោកមានសេចក្ដីសង្គ្រោះសិស្សានុសិស្ស ដោយប្រការផ្សេងៗ ជាច្រើនមហិមា ពិតមែនកាលដើមមាតាបិតា បង្កើតរូបកាយមក ហើយបីបាច់ចិញ្ចឹមបុត្រនោះមក លុះត្រាតែចំរើនវ័យវឌ្ឍនាធំឡើង ល្មមនឹងរៀនសូត្របំណេះវិជ្ជា ក៏នាំយកទៅឲ្យនៅវត្ត ប្រគេនលោកគ្រូអង្គណាមួយ ដែលលោកចេះដឹងជ្រៅជ្រះ នូវអក្ខរធម៌អក្សរក្បួនច្បាប់ សុំឲ្យលោកបង្ហាត់បង្រៀនកូនឲ្យ លោកនោះក៏ទទួលភារៈយកព្រះទ័យទុកដាក់ "ហ្វឹកហ្វឺនប្រដៅ" ឲ្យចេះដឹង តាំងពីអក្សរសាស្ត្រ សាស្ត្រាបាលីព្រមទាំងពាក្យសំដី និងកិរិយា សណ្ដាប់ធ្នាប់ឲ្យត្រឹមត្រូវ ឲ្យស្គាល់ខ្ពស់ទាបសុភាពរៀបរយ "តាមដោយគន្លងព្រេងព្រឹទ្ធបុរាណ" គឺច្បាប់ទម្លាប់ទំនឹមទំនៀម តាមបុរាណចាស់ៗ មក, លោកនេះហើយ បានឈ្មោះសន្មតហៅថាគ្រូបាធ្យាយ គឺញុំាងយើងឲ្យចេះដឹងសិល្បវិជ្ជាតាំងពួងបានជាលោកប្រៀបទុកដូចជាមាតាបិតា ។

តែក្នុងបច្ចុប្បន្នសម័យនេះ ពួកអ្នករៀនខ្លះក៏បានទៅនៅវត្តពីក្មេង ក៏មានខ្លះឪពុកម្ដាយនាំយកទៅឲ្យរៀននៅសាលាភាសាបារាំងសែស

តែម្តងក៏មាន តែទោះដូចម្តេចក៏គង់មានគ្រូបាធ្យាយបង្ហាត់បង្រៀនប្រៀនប្រដៅច្បាប់ទម្លាប់ ចំណេះវិជ្ជាសិល្បសាស្ត្រផ្សេងៗ ដែលជាសេចក្តីល្អសុចរិត, ហេតុដូច្នេះគួរសិស្សានុសិស្សគ្រប់រូប គប្បីគោរពកោតខ្លាចប្រណិប័តន៍គ្រូបាធ្យាយ តាមដំបូន្មាននៃច្បាប់ក្រមនេះកុំឲ្យឃ្លាត, ដូចមានន័យលោកពោលទុកតទៅនេះ ។

ជនអ្នកណា ធំដើរស្វែងប្រាជ្ញា ជាវិជ្ជាប្រាណា ឲ្យគិត
ជញ្ជីង រំពឹងវែងចាង កុំធ្វើបំពាន ប្រទូស្តវង្វេង ។

ខនេះគឺលោកពន្យល់ថា បើនរណាទឹងស្វែងរកចំណេះវិជ្ជាជាពន្លឺចុះឲ្យយល់ការងារ ក្នុងដំណែងរបស់ខ្លួនឲ្យបានខ្ពង់ខ្ពស់ប្រសើរនោះលោកពោលថា "ឲ្យគិតជញ្ជីង" បានសេចក្តីថា បើទឹងធ្វើកិច្ចការអ្វីត្រូវឲ្យគិតឲ្យហ្មត់ចត់ឲ្យល្អិតល្អតាមលំដាប់ច្បាប់ ដែលគ្រូប្រដៅទុកមក ត្រូវតែធ្វើកិច្ចការទាំងឡាយដោយពិនិត្យពិច័យ កុំបំពាបំពានលើសលើដំបូន្មានគ្រូ ទើបការនោះទឹងបានល្អ, ហើយលោកហាមថាកុំឲ្យ "ប្រទូស្តវង្វេង". គឺកុំចាប់ហេតុករឿងគ្រូវិញ ទោះបីគ្រូស្តីប្រដៅយើងជាសិស្ស មិនត្រូវថាគ្រូស្តីបន្ទោសដោយសំអប់ទេ ត្រូវឲ្យគិតដល់បុពណការិតមួយម៉ាត់ទៀតថា "ពាក្យពិតវែងស្វែង" ពាក្យនេះត្រូវយល់ថា ប្រៀបដូចជាអ្នកឯណាមួយប្រព្រឹត្តអំពើទុច្ចរិតមិនគប្បីទឹងគន្ធងធម៌គន្ធងច្បាប់ ហើយមានអ្នកឯណាជាមិត្តភក្តិដោយស្មោះត្រង់

គេមកស្តីពុកដាស់តឿនដោយសេចក្តីត្រឹមត្រូវ នោះអ្នកដែលជាមនុស្សអន្ធពាល ត្រឡប់ជាក្តៅក្រហាយនឹងពាក្យដែលគេស្តីពុកឲ្យល្អនោះវិញ ឬដូចជាមាតាបិតានឹងគ្រូបាធ្យាយ ឃើញកូន-ឃើញសិស្សធ្វើមោះមិនគប្បី លោកក៏ដេស្តីប្រដៅចង់ឲ្យល្អ ឯកូននឹងសិស្សនោះត្រឡប់ជាក្តៅក្រហាយទៅវិញ ត្រង់ណោះហើយគឺ "ពាក្យពិតវែងស្ងួន" ។

ហេតុនេះគួរយើងដែលជាកូនជាសិស្ស ឲ្យមានសេចក្តីពិចារណាឲ្យថែខ្លួនល្អ កុំប្រទូស្តទៅរកគ្រូដែលប្រដៅនោះឡើយ ។

ទី ១៥- ធារីបោក្រៃ ដូចអ្នកនាំផ្លូវ ដើរដោយកន្លុង នោះជិតផ្លោះទៅ ស្រុកឆ្ងាយជំងង ពិតដូចបំណង នៃចិត្តចិន្តា ។

អធិប្បាយថា ធម្មតាគ្រូបាធ្យាយនេះ លោករមែងអនុគ្រោះសិស្សានុសិស្ស ព្រមទាំងជនានុជន, លោកមានមេត្តាបង្ហាត់បង្រៀនសិល្បសាស្ត្រទាំងពួង ដល់ជនានុជនទាំងពួង ប្រុសស្រីក្មេងចាស់មិនរើសមុខ, បានជាបុរាណបណ្ឌិត លោកលើកគ្រូអាចារ្យនេះទុកជាមគ្គុនាយក សំរាប់ដឹកនាំផ្លូវ ចំណែកខាងចំណេះវិជ្ជា ឲ្យស្ទាញស្ទាត់ទៅតាមគន្លងផ្លូវ គឺច្បាប់ក្បួនដំកប់ដំកា, ព្រោះបុរជនទាំងឡាយកាលនៅជាកុមារតូចៗ នៅឡើយ ពុំទាន់ចេះវិជ្ជាអ្វី, លុះចូល

ទៅកាន់សំណាក់គ្រូអាចារ្យហើយ សុំឲ្យលោកប្រៀនប្រដៅ លោកក៏មេត្តាបង្ហាត់បង្ហាញ ឲ្យរៀនសរសេរស្រៈព្យញ្ជនៈ មើលសាស្ត្រាបាលីច្បាប់ក្បួន រៀនគិតលេខបូកសងគុណ ហារឲ្យស្ទាត់គ្រប់បែប. បែកខាងអក្សរសាស្ត្រ ព្រមទាំងគំនូរគូរលេសជារូបភាពផ្សេងៗ បានការ ; ហើយ លោកប្រៀនប្រដៅ ឲ្យប្រព្រឹត្តកិរិយាមារយាទឲ្យត្រឹមត្រូវ តាមគន្លងធម៌ ទំនងទំនៀមទម្លាប់ច្បាប់សណ្ដាប់ប្រវេណី គឺឲ្យដឹងខុសត្រូវបុណ្យបាបគុណទោសជាដើម ។ល។ ហើយលោកអធិប្បាយពន្យល់ អំពីអំពើពាលទុច្ចរិត ហាមឃាត់មិនឲ្យធ្វើបញ្ចវេរទាំង ៥ មានសម្លាប់សត្វជាដើម មានផឹកសុរាមេរ័យជាបរិយោសាន, ដាស់តឿនឲ្យធ្វើតែអំពើសុចរិតល្អ មានឲ្យកាន់រក្សាសីលជាដើម, ហេតុនេះហើយទើបលោកពោលថាគ្រូអាចារ្យជាអ្នកនាំផ្លូវសិស្សានុសិស្ស ។

ចំណែកឯសិស្សបានយកចិត្តទុកដាក់ ខំឧហាត់សង្កត់រៀនតែងត្រាប់តាមច្បាប់ទំនៀមរបស់គ្រូអាចារ្យបុរាណហើយនោះ លោកទុកសិស្សនោះជាអ្នកដើរតាមដានផ្លូវត្រូវប្រៀនប្រដៅ ក៏សឹងបានសំរេចប្រយោជន៍ដូចបំណង ដោយអំណាចចំណេះវិជ្ជាដែលចេះដឹងនោះ បានជាលោកប្រៀបទុកថាដូចជាអ្នកត្រាច់ចោរទៅស្រុកធំតូច ស្គាល់ផ្លូវប្រាកដរមែងនឹងដល់ដូចប្រាថ្នា ។

បើសិស្សណា មិនកាន់ច្បាប់ដំកប់គ្រូអាចារ្យប្រៀនប្រដៅមកទេ ធ្វើតាមតែអំពើចិត្តឯង លោករមែងតិះដៀលដូចន័យតទៅនេះ ៗ

រីឯចេះឯង ដូចអ្នកវង្វេង កណ្ដាលអធ្ងាត់
ពុំនោះដូចខ្វាក់ តែម្នាក់អាត្មា ចរចេញយាត្រា ឥត
អ្នកដឹកដៃ ៗ ស្វះស្វែងរកផ្លូវ ពុំដែលដឹងត្រូវ ដើរ
ពាលឃព្រៃ ហេតុដូច្នេះឯង ឥតអ្នកដឹកដៃ ចិត្ត
នោះសង្ស័យ ដូចដល់ពុំដល់ ៗ

បានសេចក្ដីថា វិស័យធម្មតាមនុស្ស បើចេះដឹងឯងនូវកិច្ចការអ្វី ឥតមានគ្រូអាចារ្យបង្ហាត់បង្ហាញណែនាំពន្យល់ ឲ្យភ្លឺយល់ជាក់ច្បាស់ទេ រមែងធ្វើការអ្វីមិនល្អបាន មិនបានសំរេច ៗ

ប្រៀបដូចជាមនុស្សវង្វេងផ្លូវ ហើយដើរត្រាច់កាត់ព្រៃព្រឹក្សតែម្នាក់ឯង, ឬដូចមនុស្សខ្វាក់នេត្រទាំងពីរ ចរចេញទៅកាន់ដំបន់ឋានណាឥតអ្នកដឹកដៃ មនុស្ស ២ ជំពូកនេះទោះបីខំប្រឹងពត់ស្ទាបរកផ្លូវក៏ពុំត្រូវតាមផ្លូវដែលស្រួលដែលល្អ សូម្បីបើដល់ទីបំណងខ្លួនហើយ ក៏នៅតែសង្ស័យក្រែងពុំទាន់ដល់, ទោសទាំងនេះ ម្នាក់មកពីខ្វាក់ភ្នែក ឥតអ្នកដឹកដៃ, ម្នាក់ភ្នែកភ្លឺក៏មែន តែមកពីវង្វេងចំណេះល្ងង់ខ្លៅ ឥតគ្រូបាធ្យាយប្រៀនប្រដៅ នូវវិជ្ជាផ្សេង ៗ. បានជាពុំអាចយល់កិច្ចការទាំងពួងបាន បើមានចំណេះបន្តិចបន្តួចក៏ពុំបានជាពូកែ យកជាការពុំបានពិតប្រាកដ,

ដូចជាវិទ្យាអក្សរសាស្ត្រ, បើពុំបានពិចារណា តាមក្បួនខ្នាតឲ្យមួនមាំ គ្មានគ្រូពន្យល់វិធីអក្ខរៈ ឬក៏ប្រែសព្ទផ្សេងៗ ឲ្យយល់ក្លីច្បាស់ នោះរមែងសរសេរដែលខុសទៅជាធម្មតា ហើយខ្លួនអ្នកសរសេរពុំអាចដឹងបានថាខ្លួនសរសេរខុសផង, ព្រោះមកពីមិនមានចំណេះវិជ្ជាទាំងពួងឲ្យស្ទាត់មួនមាំ តគ្រូបាធ្យាយណានាំពន្យល់ឲ្យក្លីច្បាស់ ទោះបីខុសក៏ពុំដឹងជាខុស បេះតែស្មានថាត្រូវហើយ បានជាលោកប្រៀបទុកដូចមនុស្សវង្វេងផ្លូវ មនុស្សខ្វាក់ភ្នែកទាំងសងខាងនោះឯង ។

ទោសទាំងនេះ អ្នកទាំងឡាយកុំគប្បីធ្វេសប្រហែស បើចង់ចេះចំណេះវិជ្ជាសិល្បសាស្ត្រទាំងពួង ត្រូវតែរៀនពីគ្រូអាចារ្យ យកបែបផែនគ្រូអាចារ្យ សំគាល់ទុកក្នុងចិត្តឲ្យមួនមាំ ទើបលោកពប់ថាជាពហុស្សូតអ្នកចេះចាំច្រើន ។

ទី ១៦ - នេះដូចអ្នកជង ពុំដោយកន្ទង់ នៃលោកណាយល់ សឹងធ្វើមោហោ ធោសោកាំហល់ ពុំអាចចប់ចល់ ឆាឆ្ងង់ឆាស្រាល ។

ពួកមនុស្សដែលមានកិរិយាប្រព្រឹត្ត មិនប្រសើរ គឺមានមារយាទអាក្រក់សណ្តាប់ធ្នាប់អាក្រក់ ប្រព្រឹត្តអាក្រក់ ចិត្តអាក្រក់ ទាំងនេះ មកពីសន្តានចិត្តអន្ធពាល ព្រោះពាលមានលក្ខណៈ ៣ យ៉ាង គឺគិតអ្វី គិតតែពីសេចក្តីអាក្រក់នេះ១, ធ្វើកិច្ចអ្វី ធ្វើតែកិច្ចអាក្រក់នេះ២, បើពោល

វាចាអ្វីក៏ពោលតែវាចាអាក្រក់នេះ ៣, ហេតុនេះហើយ បានជាលោកពោលថាមនុស្សពាលនោះ "ពុំដោយគន្ធ នៃលោកណាយល់" គឺថា សុភាសិត ឯណាជាពុទ្ធភាសិតឬបុរាណភាសិត ដែលល្អប្រពៃ ហើយមាតាបិតាគ្រូអាចារ្យ លោកនាំយកមកទូន្មានប្រៀនប្រដៅកូននិងសិស្សឯណាដែលប្រព្រឹត្តអាក្រក់ កូននិងសិស្សនោះជាមនុស្សពាល មិនស្តាប់គ្រាប់ត្រង់យក ថែមទាំងសំដែងអាការក្រេវក្រោធចេញមកឲ្យឃើញដល់កុមហាជនពល់គ្នាទៀត, ដូចន័យលោកពោលថា "សឹងធ្វើមោហោ ទោសោកំហល់ ពុំអាចទប់ទល់ នាធ្ងន់នាស្រាល" បានសេចក្តីថាបុត្រនិងសិស្សនោះជាមនុស្សពាល លុះឮមាតាបិតាគ្រូអាចារ្យស្តីប្រដៅឲ្យល្អ ក៏កើតបដិឃៈ ក្តៅខ្ញាញ់ ក្នុងហទយតែក្រេវក្រោធខឹង ពុំអាចអត់សង្កត់ចិត្ត ឲ្យស្ងប់រំងាប់បានឡើយ ម្ល៉ោះហើយក៏ធ្វើយកតបទៅកាន់លោកអ្នកដ៏មានគុណនោះវិញ , ទោសនេះមកពីសិស្សនោះកូននោះ ជាមនុស្សពាលខ្លៅល្ងង់ រមែងញុំាងសន្តានចិត្ត ឲ្យមានទោសមកជាលំដាប់ ហើយបញ្ចេញកំហឹងឲ្យពោលពាក្យមិនគប្បីមានប្រការផ្សេងៗ នេះមកពីមិនស្គាល់ធ្ងន់ស្រាល ។

ហេតុនេះយើងទាំងឡាយ កុំគប្បីយកជំពប់ចរិតសិស្សឬកូនកំហល់ទាំងនោះជាគំរូយ៉ាងឡើយ ត្រូវចាំពាក្យចាស់ ១ ម៉ាត់ទៀតថា "សិស្សប្រាជ្ញវៀតគ្រូ ជេរពោលដំរាយ" នេះជាឧសថដ៏ប្រសើរ សំរាប់

តែទឹកចិត្តសិស្សទាំងកូនដែលមោហោនោះ ឲ្យស្គាល់គុណ គ្រូអាចារ្យ មាតាបិតាដែលមានលើខ្លួន ។

ទី ១៧- ប្រដៅក្តីច្បាប់ សឹងជាពុំគាប់ ហេតុពិត្តអន្ធពាល ក្តីច្បាប់ធម្ងន់ សឹងថាជាស្រាល ហេតុចិត្តអន្ធពាល ចង់តែសប្បាយ ។

ពាក្យមួយបទនេះ មានទំនងជាធម្មតា គ្រូអាចារ្យរមែងតែងតែបង្រៀនទូវក្បួនច្បាប់ដែលមានខ្លឹមសារគម្ភីរភាពជ្រាលជ្រៅ សព្វគ្រប់ ដើម្បីឲ្យសិស្សទោះដឹងនឹងប្រព្រឹត្តប្រតិបត្តិតាម, តែសិស្សខ្លះជាមនុស្សមានសន្តានចិត្តជាអន្ធពាលទុរាចារ, ប្រៀបដូចមនុស្សខ្វាក់ឬថ្លង់គ ឬកាប់ឥតប្រាជ្ញាពុំឈ្លាសវៃ ពុំយល់ន័យអត្ថរសប្រស្នា វាចាដែលគ្រូពោលប្រដៅពន្យល់នោះ ត្រឡប់ជាពុំគាប់ចិត្តខ្លួនវិញ ហើយលបគិះដៀលចាប់ទោសគ្រូថា គ្រូស្អប់ខ្លួន គ្រូគ្មានមេត្តាករុណា ។ល។ ព្រោះដោយហេតុពាក្យប្រដៅនោះ ពុំត្រូវចំណុចចិត្តខ្លួន ដែលជាមនុស្សពាលចង់តែសប្បាយ មានបំណងចង់សេពសេពលេងល្បែងទាំងពួងជាដើម, ទីងបានគេត្រូវគ្មានថាខុសគាប់យ៉ាងណាក៏ទេ ទីងបានដឹងថាបទនេះល្មើសខុស នឹងផ្លូវសុចរិតក៏ទេ ឬដឹងខ្លះដែរ តែចិត្តមាំះ ថាការបន្តិចបន្តួច ជាកិច្ចកំសាន្តសប្បាយប៉ុណ្ណោះមិនទៅជាអ្វី បើខុសនឹងច្បាប់ ក៏ពុំធ្ងន់ប៉ុន្មានទេ ក៏ធ្វើលោកបំពានទៅ, មនុស្សប្រមាទបែបនេះ ច្រើនតែ

ភ្ញាក់ចំណាប់ពុំសូវការ , ព្រោះដោយចិត្តអន្ធពាល ពុំប្រព្រឹត្តតាមដំបូន្មានគ្រូអាចារ្យប្រៀនប្រដៅ ប្រយោជន៍ឲ្យខ្លួនបានសេចក្តីល្អសុចរិតនោះឡើយ ។

សិស្សដែលបើងរឹងរូសយ៉ាងនេះ តើមកពីហេតុអ្វី? លោកប្រាប់ទោសថា ព្រោះ

ពុំដឹងដើមត្រូ បង្កើតអត្តភាព ប្រដូចផ្លូវម្តាយ ក្តីពី មនុស្សលោក រួចដល់សួគ៌ាលយ ចៀសចតុរាបាយ ជាការនាំដំបូង ។

បានសេចក្តីថា សិស្សដែលជាពាលនោះ មកពីពុំដឹងហេតុបំណាច់របស់គ្រូអាចារ្យ ដែលលោកមានប្រាថ្នា ចង់ឲ្យសិស្សានុសិស្ស បាននូវប្រយោជន៍ យ៉ាងខ្ពស់ក្រៃលែងដល់ខ្លួន, គឺលោកបំភ្លឺពីផ្លូវច្បាប់ការអាណាចក្រ ដើម្បីឲ្យសិស្សនោះបានសេចក្តីចំរើនរុងរឿងឧត្តុង្គឧត្តមក្នុងលោកិយនេះ ១ ឲ្យក្តីក្នុងផ្លូវពុទ្ធសាសនា ដើម្បីយកមគ្គផលឲ្យរួចចាកចតុរាបាយ នរកទាំងបួន ក្នុងបរលោកនាយនេះ ២, ហេតុនេះបានជាលោកទុកគ្រូអាចារ្យ "ប្រដូចនូវម្តាយ" ព្រោះម្តាយបង្កើតរូបកាយ ឧបត្ថម្ភចិញ្ចឹមបីបាច់ថែរក្សា ឯចំណែកគ្រូអាចារ្យ ជួយឧបត្ថម្ភទំនុកបំរុង ក្នុងកិច្ចបង្ហាត់បង្រៀន ឲ្យកើតចំណេះវិជ្ជាផ្សេងៗ បានជាលោកប្រៀបដូចមាតា ។

មួយវិញទៀត បើសិស្សឯណា មានប្រាជ្ញាអាចយល់នូវគុណជាតិ នៃការសិក្សាទាំងនេះបានច្បាស់ហើយ នោះគប្បីកាន់ដោយមាំមួន នូវការសិក្សាដែលជាមធុរស ដូចមានតទៅនេះ ។

ឆាបីហៅគ្រូ កុំធ្វើមួម្ទ ចិត្តដោះឲ្យស្លូន កុំធ្វើធំកើង ចង់ធំតែខ្លួន ក្រែងបាបមកជួន នៅនាលោកិយ ។

លោកថា បើសិស្សណា បានយល់ក្តីនូវគុណូបការៈរបស់គ្រូ ហើយគួរគោរពប្រណិប័តន៍ មិនត្រូវធំកើងឫកពាក្យអឺតធ្វើងដៃឃើញ គ្រូហើយធ្វើឫកកញ្ចប់កញ្ចូរដាក់គ្រូឡើយ ។

ទុកណាជាខ្លួន មានយសស័ក្តិធំជាងក្តី មានសម្បត្តិទ្រព្យច្រើន ជាងក្តី ត្រូវតែធ្វើចិត្តឲ្យស្លូន ដាក់ខ្លួនឲ្យទាបជាងគ្រូ គោរពខ្លាចដោយ គោរពស្មោះត្រង់កុំគប្បីភ្លេច, បើសិស្សណាមិនគោរពគ្រូ លោកពោល ថា "ក្រែងបាបមកជួន នៅនាលោកិយ" បានសេចក្តីថា បណ្តាសិស្ស ណា ពុំដឹងគុណគ្រូ ពុំគោរពគ្រូ អ្នកនោះនឹងបានបាបគឺសេចក្តី អាក្រក់ ដល់ខ្លួនថាជាមនុស្សអកតញ្ញូ ក្នុងនាលោកិយនេះពុំខាន ។

ទី ១៨ ក្រែងថាញយ អាចឲ្យពណ្ណកាយ មានរូបរស្មី ហើយឲ្យរុងរឿង អស់បញ្ចង្គ្រិយ ស្មើព្រះឥន្ទធី ជនការ ស្រាតហោង ។

សេចក្ដីនេះ ប្រៀបបីដូចពេទ្យ ដែលពូកែបំណាច់ខាងរោគពេន ភ្នែក ទោះបីភ្នែកនោះឈឺចាក់ដោត រងទុក្ខវេទនា អាចស្រវាំង មើលអ្វីពុំច្បាស់ លុះពេទ្យប្រគបថ្នាំដាក់ភ្នែកឲ្យ ភ្នែកនោះក៏ជាស្រឡះ ភ្លឺច្បាស់ឡើងល្អ ជាធម្មតាវិញ នេះមានឧបមាយ៉ាងណា ?

សមគ្នានឹងអ្នករៀនវិជ្ជា ការដើមហាក់ដូចជាមនុស្សខ្វាក់ គ្រូអាចារ្យ ដូចពេទ្យហ្នឹង, គ្រូបង្ហាត់បង្ហាញសិស្ស នូវសិល្បសាស្ត្រផ្សេងៗ សិស្សដែលខំសង្កាត់រៀនសូត្រ ចាំពាក់រង់ទទួលយកចំណេះពីគ្រូនោះយូរទៅសឹងមានប្រាជ្ញាឈ្លាសវៃ ភ្លឺសេចក្ដីគ្រប់ជំពូកៗ, ស្រេចបរិបូណ៌ហើយ លោកជូនឲ្យចេញប្រឡង, បើជាប់លេខមានសញ្ញាប័ត្រទើបសន្មតហៅថាជាអ្នកមានវិជ្ជាដ៏ប្រសើរ រាជការដែនដី ក៏យកទៅប្រើតាំងឲ្យរុងរឿង មានយសសក្ដិប្រាក់ខែជាន្ទាច់, ហេតុនេះហើយដែលគ្រូអាចារ្យ ធ្វើឲ្យសិស្សបានចំរើន បានជាពោលទុកថា "ល្អគ្រូដូចទី ដូនកំសាកហោង" ។

ឯឧបការគុណរបស់មាតាបិតានោះ លោកសំដែងថា

ព្រះជននគរសោភណា បង្កើតអាត្មា ឲ្យមានសរីរ
ជនង រក្សាពីតូច មិនឲ្យមានហ្មង អស់សុខទុក្ខជង
រុំដែលជិតដ្ឋង ។

សេចក្តីថា អាពុកម្តាយបង្កើតយើងមក លោកចិញ្ចឹមយើងបីបាច់រក្សាល្អណាស់ មានបំបៅដោះផ្តល់ទឹកបញ្ចុកបាយជាដើម លុះដល់ធំឡើង លោកនៅតែគ្រប់គ្រងរក្សា តែងតែទទួលទុក្ខសុខ របស់បុត្រធីតាពុំដែលធុញទ្រាន់ឡើយ, ថាបើកូនឈឺចាប់ ឬមានទុក្ខដូចម្តេចៗក្តី ឬមួយទៅប្រព្រឹត្តទុច្ចរិតល្មើសនឹងច្បាប់ ត្រូវមានទុក្ខទោសដូចម្តេចៗក្តី នោះចិត្តមាតាបិតា ក៏រមែងព្រួយផងពុំមានភ្លេច, មានខ្លះសង្គ្រោះរហូតជួយសងបំណុលជួស ខ្លះឲ្យសម្បត្តិទ្រព្យទៅកូនដែលក្រលំបាក យកទៅលក់ចាយចិញ្ចឹមជីវិតក៏មាន ។ល។ ទាំងនេះគឺមកតែមាតាបិតាលោកមានសេចក្តីមេត្តាករុណា ដល់បុត្រធីតានោះ ។

រួមសេចក្តីទៅឃើញថា មាតាបិតានិងគ្រូអាចារ្យនេះជាទុល្លភជនរបស់បុត្រនិងសិស្ស ដូចន័យអធិប្បាយមកនេះ ។

ទី ១៩ - ព្រះជនកព្រះជននី បើនឹងស្រដី ប្រសើរពេកពន់ ជាភ្នំព្រះសុមេរុ នោះហោចមហាធ្ងន់ ជាបើនឹងគណនា ពុំអាចគាំទ្រ ។

បើនឹងពណ៌នា សរសើរពីគុណមាតាបិតា ដែលមានលើកូនប្រុសកូនស្រីទាំងឡាយ សំងឃើញថាជាច្រើនក្រៃពេកឥតរកអ្វីនឹងលើកយកមកប្រៀបធៀបឲ្យស្មើនោះពុំបានឡើយ ប្រសើរក្រៃពេកណាស់, ទើបលោកប្រៀបថា ភ្នំព្រះសុមេរុ ជាបព៌តដ៏ធំឥតឧបមា

ខ្ពស់ហួសប្រមាណ លើសលែងបព្វតាទាំងពួង គុណទ្វីបទាំងបួននេះ ថាបើទឹកត្រូវទៅឯទន្លេទៀត លោកថា “នោះហៅថាមហាទូទ” ជួនពន់ពេកហួសប្រមាណ “ថាបើទឹកគណនា ពុំអាចកន្ទង” លោកថាបើទឹកថ្មីយកទម្ងន់វិញ ក៏ពុំអាចទឹកថប់ដោយវិធីសំខាន់ថាប៉ុណ្ណោះៗ ពុំបាន ។ បើទឹកលើកយកទំហំ, កំពស់ទឹកទម្ងន់ក្នុងព្រះសុមេរុកេជ មកផ្ទឹមទឹកទំហំកំពស់ទម្ងន់គុណមាតាបិតា ដែលមានគុណលើបុត្រធីតា នោះឃើញថាពុំអាចទឹងរំលងកន្ទងកើនហួសឬពុំស្មើបានឡើយ, ដូច្នេះហើយយើងជាបុត្រធីតាកុំគប្បីភ្លេចគុណមាតាបិតារបស់យើងគ្រប់រូប ដែលមានព្រះគុណធ្ងន់ជាងភ្នំព្រះសុមេរុនោះឡើយ ។

មិនតែគុណមាតាបិតាប៉ុណ្ណោះទេ លោកក្រាបតទៅទៀតថា,

វ៉ែក្រទាញព្រួយ ប្រដូចឆ្លូវម្តាយ អាពុកការឃ្លង់ហោង
អាចឲ្យត្រាំច្បាប់ ប្រដៅឲ្យមិនដង ដោយផ្លូវគន្លង ព្រះ
ពុទ្ធនាំងឡាយ ។

បានសេចក្តីថា បណ្ដាបុព្វការីរបស់យើង មិនតែឪពុកម្តាយប៉ុណ្ណោះទេ លោកកប់យកគ្រូបាធ្យាយបញ្ចូលមកទៀត ជាបុគ្គលដែលមានគុណលើយើង ដែលស័ក្តិសិទ្ធិស្មើនឹងឪពុក-ម្តាយយើង ដូចបានអធិប្បាយមកខ្លះហើយខាងដើម, តែក្នុងទីនេះលោកលើកយកខ្លួនធម្មកថា នៃគ្រូបាធ្យាយយើងទៀតថា “អាចឲ្យ

ក៏ច្បាប់ប្រដៅធម៌ផង ដោយនូវគន្លង ព្រះពុទ្ធទាំងឡាយ" ថា គ្រូបាធ្យាយ ប្រដៅយើងជាសិស្សឲ្យដឹងច្បាប់ទម្លាប់ជាគតិលោក ហើយប្រដៅនូវធម៌ តាមដោយគន្លង ដែលព្រះបរមគ្រូសព្វញ្ញុពុទ្ធ ព្រះអង្គទ្រង់ត្រាស់សំដែងទុកមកជាច្បាប់សំរាប់ឲ្យពួកពុទ្ធបរិសទ្យបដិបត្តិតាម ដើម្បីជាប្រយោជន៍ ដឹកនាំសិស្សឲ្យបានជាមនុស្សល្អក្នុងលោកនេះប្រការ ១ ឲ្យរួចចាកទុក្ខ ក្នុងជាតិនេះនឹងជាតិក្រោយនេះប្រការ ១ ។

គ្រូបាធ្យាយមានគុណវិសេសយ៉ាងនេះ បានជាលោកលើកយកមកតាំងទុកដូចមាតាបិតារបស់យើង ។

ទី ២០- នរអ្នកណា នោះមានប្រាជ្ញា ឲ្យគិតវែងឆ្ងាយ គុណនោះនាំផលី ហោមបានឆ្ងាយ កុំឲ្យអន្តរាយ ក្តីពិព្យាយាម ។

អ្នកទាំងឡាយ កាលណាបើមានវិជ្ជា ចេះច្បាប់សំរាប់រក្សាខ្លួនបានហើយ ទាំងខាងអាណាចក្រនិងពុទ្ធចក្រ សតិបញ្ញាក៏ល្អមានគ្រាន់ប្រើប្រាស់បានតាមសតិកំឡាំង នោះត្រូវឲ្យមានយោបល់ យល់គិតអំពីគុណលោកអ្នកមានគុណ ឲ្យចាំមួនកុំភ្លេចប្រហែស, បានជាលោកប្រដៅចារិកទុកថា "នរអ្នកណា នោះមានប្រាជ្ញា ឲ្យគិតវែងឆ្ងាយ" បានសេចក្តីថា ធម្មតាបណ្ឌិតជាតិ លោករមែងគិតពីអ្នកមានឧបការ-

គុណកុំភ្លេច ព្រោះលោកប្រកបដោយសេចក្តីជាអ្នកមានកតញ្ញូ ។ ចុះចំណែកយើងជាកូនទង់មាតាបិតា ជាសិស្សទង់គ្រូអាចារ្យ តើត្រូវធ្វើដូចម្តេច? ទើបហៅថា ជាអ្នកមិនភ្លេចគុណ, ដូច្នេះលោកវិនិច្ឆ័យប្រាប់ជាបញ្ហាថា "គុណនេះទាំងបី ហៅមហាទូលាយ" គឺលោកជាមាតាបិតានិងគ្រូអាចារ្យ ទាំងបីនេះ លោកមានឧបការគុណ លើសលន់ពន់ពេកជាអនេកប្បការ លើកូននិងសិស្ស, គុណទាំងនោះធ្ងន់ក្រៃលែងលើសទម្ងន់ភ្នំព្រះសុមេរុពេកទៅទៀត, ដូច្នេះឯងហើយ ទើបលោកទូន្មានយើងថា "កុំឱ្យអន្តរាយ ក្តីពិតព្យាយាម" ថាកុំឱ្យភ្លេចគុណនោះឱ្យសោះ, ត្រូវឱ្យចាំជាប់ក្នុងចិត្ត ថាមាតាបិតាគ្រូអាចារ្យរបស់យើងនេះ លោកមានគុណនឿយហត់បីបាច់ចិញ្ចឹមរក្សាយើង, បង្ហាត់បង្ហាញចំណេះវិជ្ជាផ្សេងៗ ឱ្យយើងចេះដឹង បើលើកឃើញដូច្នេះហើយត្រូវមានព្យាយាម ធ្វើភក្តិបដិបត្តិកុំឱ្យដាច់ មានគោរពក្រាបសំពះជាដើម, បើនឹងពោលឱ្យពិស្តារបន្តិច ថាយើងត្រូវធ្វើបដិការៈផ្គត់ផ្គង់ទូវភោជនាហារព្រមទាំងសំពត់គាវសាវស្បង់, បើលោកមានជម្ងឺព្យាធិមកបៀតបៀន យើងជាកូនត្រូវរកពេទ្យមើលដាក់ថ្នាំត្រាំអម្ចី ដូចកាលលោកថែទាំយើងពីតូចមក ។

មួយទៀតព្រះរតនគុណ គឺព្រះពុទ្ធព្រះធម៌ព្រះសង្ឃ ដែលលោកជាអ្នកចង្កូតតម្រង់ផ្លូវយើង ទៅកាន់សេចក្តីសុខ ។

ព្រះពុទ្ធលោកជាអគ្គបុគ្គល លោកឆ្ងាយចាកកិលេស ត្រាស់ដឹងឯងប្រពៃ ហើយទ្រង់ផ្សាយនូវធម៌ដែលកំបាំង ដោយអំណាចសីលសមាធិបញ្ញាដ៏បរិសុទ្ធរបស់ព្រះអង្គ, ទើបទ្រង់ព្រះនាមថាព្រះសម្មា-សម្ពុទ្ធ ។

ព្រះធម៌ គឺព្រះពុទ្ធវចនៈ ដែលព្រះពុទ្ធអង្គទ្រង់ត្រាស់ទូន្មានសត្វលោកដើម្បីដឹកនាំឲ្យវៀរចាកអកុសលកម្ម, ដោយព្រះមហាករុណាប្រោសបំឡងសត្វឲ្យរួចចាកទុក្ខវេទនា ។

ព្រះសង្ឃជាសាវកព្រះដ៏មានព្រះភាគ លោកបដិបត្តិប្រពៃហើយ ជាបុញ្ញក្ខេត្តដ៏ឧត្តម របស់សត្វលោក ។

ដូច្នេះយើងត្រូវគោរពគុណទាំងបីនេះទៀត ជាបុញ្ញាភិរបស់យើង, ដូចពោលខាងក្រោយនេះតទៅទៀតថា ។

រីបុណ្យឆ្លឺឆាយ អំពើសុភាព នោះវាតែងតាម
ប្រដូចស្រមោល អន្ទោលតាមប្រាណ ពុំដែលចៀស
ឃ្លាត ត្រង់ត្រឹសល់វល់ ។

ថាបើយើងពុំភ្លេចគុណលោកទាំងនេះទេ យើងនឹងបានបុណ្យ គឺសេចក្ដីសុខចំរើនយសស័ក្ដិ នូវភោគសម្បទ ដោយអំណាចផលបុណ្យកតញ្ញូនោះ តែបើយើងប្រមាទធ្វេសប្រហែស បំភ្លេចបំបាត់គុណ

ទាំងនោះហោលអស់ហើយ, យើងនឹងបានបាប គឺសេចក្ដីវេទនា ត្រលំបាកគោកយាំកលោមល្ហាម ។

ឯផលបុណ្យនឹងបាប - ទាំងពីនេះ, លោកប្រៀបដូចស្រមោលនៃរូបយើង រមែងតែជាប់ដិតនឹងខ្លួនយើងពុំដែលឃ្លាត ឯយើងសោតក៏ពុំអាចនឹងចៀសឲ្យផុតបាន, បើយើងធ្វើអំពើល្អ បុណ្យគង់កើតមានដល់យើង, បើយើងធ្វើអំពើអាក្រក់ បាបក៏គង់មានដល់យើង, យ៉ាងនេះយើងត្រូវប្រព្រឹត្តតាមច្បាប់ក្រមនេះឲ្យបរិបូណ៌ ។

ទី ២១ - ឲ្យតែតាំងញ៉ឹង ហើយឲ្យរំពឹង ប្រាជ្ញាឲ្យយល់ ឲ្យមានការយំ សព្វកុសល កុំធ្វើសល់រលំ នឹងក្ដីទុក្ខសោក ។

អធិប្បាយថា ធម្មតាជាមនុស្សនេះ ឲ្យយកប្រាជ្ញាត្រិះរិះពិចារណាកើង ឲ្យមានជាប់ក្នុងខន្ធសន្ដាន គឺឲ្យខំប្រឹងព្យាយាមកសាងកុសលកាន់ទៀងត្រង់សុចរិតធម៌ មានរក្សាសីល ៥ ចាំសីល ៨ ចំរើនមេត្តាករុណាកុំឲ្យដាច់ "កុំធ្វើសល់រលំ នឹងក្ដីទុក្ខសោក" គឺលោកឲ្យលះបង់អំពើទោស ទុក្ខនឹងសោកហោលចេញ កុំឲ្យមាននៅក្នុងសន្ដានចិត្ត ព្រោះសេចក្ដីសោកស្រណោះនេះ ឥតអំពើទេ ហើយជាមន្ទិល នាំឲ្យសត្វវិលវល់ក្នុងវដ្ដសង្សារ ត្រូវឲ្យជឿថាជីវិតមិនទៀង រូបមិនទៀង រូបនេះមិនមែនជារបស់យើង ។ល។ បើអ្នកឯណាប្រដៅចិត្ត ឲ្យចុះកាន់

គន្ធធម៌បានដូច្នេះហើយ, ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សរសើរដូចមានន័យតទៅនេះ ។

នរអ្នកណា  នឹងនាំអាត្មា  ឧស្សាហ៍អន្លោក
ស្វែងធម៌ជាផ្លូវ  ទៅកាន់បរលោក  ចូលមហាបាដិ-
មោក្ខ  គឺនិព្វានហោង ។

អធិប្បាយថា  បើបុគ្គលឯណាខំប្រឹងប្រែង  ធ្វើចិត្តឲ្យល្អស្អាត សង្អាតកោសរូសកិលេស មានលោភៈ ទោសៈ មោហៈ ជាដើម ដែលជាគ្រឿងសៅហ្មងចិត្ត ឲ្យស្ដើងរលីងអស់ទៅនេះហៅ "ស្វែងធម៌ជាផ្លូវទៅកាន់បរលោក" ទើបបាននាំខ្លួន ឲ្យបានសេចក្ដីសុខ ទៅលោកខាងមុខ "ចូលមហាបាដិមោក្ខ គឺនិព្វានហោង" លុះបានឃើញច្បាស់ នូវអរិយសច្ចធម៌ទាំង ៤ តាមពិតហើយក៏កើតសេចក្ដីនឿយណាយក្នុងខន្ធទាំង ៥ ហើយដំណើរទៅតាមផ្លូវធំ គឺព្រះអដ្ឋង្គិកមគ្គជាផ្លូវត្រង់ ចូលទៅកាន់ស្ថានព្រះបរមនិព្វាន ជាឯកន្តសុខនោះឯងហោង ។

ចប់ច្បាប់ក្រមចរិយាយប៉ុណ្ណោះហោង ។

# បញ្ជីស្រង់ចំនួនចៅអធិការនិងមន្ត្រីសង្ឃ

ដែលទើបតាំងថ្មីក្នុងគណៈខេត្តកំពត-អ៊ិត ឆ្នាំ ១៩៤៤

១- សញ្ញាប័ត្រលេខ ៥១ ចុះថ្ងៃ ២៨-៧-៤៤ តាំងព្រះគ្រូឧត្តមមុនី ម៉ុន-សេស កើតឆ្នាំខាល អាយុ ៥៤ វស្សា ៣៤ ជាចៅអធិការ វត្តមហាមន្ទ្រី ឃុំលេខ៤ ក្រុងភ្នំពេញ ។

២ - សញ្ញាប័ត្រលេខ ៥២ ចុះថ្ងៃ ៦-៨-៤៤ តាំងលោកគ្រូ ណុប-ហុក កើតឆ្នាំឆ្លូវ អាយុ ៥៥ វស្សា ៥ នាមងារ ហន្តត្ថេរ ជាចៅអធិការ វត្តកំស ឃុំសឹងគោល ស្រុក-ខេត្តកំពត ។

៣ - សញ្ញាប័ត្រលេខ ៥៣ ចុះថ្ងៃ ៦-៨-៤៤ តាំងលោកគ្រូប៉ុក-ឆន កើតឆ្នាំជូត អាយុ ៣២ វស្សា ១០ នាមងារ គម្ពីរត្ថេរ ជាចៅអធិការ វត្តក្រាលមាស ឃុំក្រាលមាស ស្រុក-ខេត្តកំពត ។

៤- សញ្ញាប័ត្រលេខ ៥៤ ចុះថ្ងៃ ៦-៨-៤៤ តាំងលោកគ្រូលៀង-ឃុត កើតឆ្នាំរកា អាយុ ២៥ វស្សា ៥ នាមងារ សុវណ្ណជោត ជាចៅអធិការ វត្តអង្គរធំ ឃុំបឹងគោល ស្រុក-ខេត្តកំពត ។

៥ - សញ្ញាប័ត្រលេខ ៥៥ ចុះថ្ងៃ ៦-៨-៤៤ តាំងព្រះវិន័យធរ យស់-នាង កើតឆ្នាំមមី អាយុ ៦៣ វស្សា ៤២ នាមងារ ធម្មត្ថេរ ជាចៅអធិការ វត្តស្នំអំពិល ឃុំសឹងគោល ស្រុក-ខេត្តកំពត ។

៦ - សញ្ញាប័ត្រលេខ ៥៦ ចុះថ្ងៃ ៦-៨-៤៤ តាំងលោកគ្រូកៅ-អ៊ុន កើតឆ្នាំមមែ អាយុ ៦២ វស្សា ៤១ នាមឆាយា ឥន្ទត្ថេរ ជាចៅអធិការ វត្តពិជ័យឧដុង្គ ឃុំកំពត ស្រុក-ខេត្តកំពត ។

៧ - សញ្ញាប័ត្រលេខ ៥៧ ចុះថ្ងៃ ៦-៨-៤៤ តាំងលោកគ្រូអ៊ុង-អ៊ិន កើតឆ្នាំមមី អាយុ ២៧ វស្សា ៧ នាមឆាយា ឥន្ទត្ថេរ ជាចៅអធិការ វត្តកូនសត្វ ឃុំកូនសត្វ ស្រុក-ខេត្តកំពត ។

៨ - សញ្ញាប័ត្រលេខ ៥៨ ចុះថ្ងៃ ៦-៨-៤៤ តាំងលោកគ្រូយួន-សាញ់ កើតឆ្នាំម្សាញ់ អាយុ ២៦ វស្សា ៦ នាមឆាយា មុនិសមុទ្ទត្ថេរ ជាចៅអធិការ វត្តរការ ឃុំកោះតូច ស្រុក-ខេត្តកំពត ។

៩ - សញ្ញាប័ត្រលេខ ៥៩ ចុះថ្ងៃ ៧-៨-៤៤ តាំងលោកគ្រូកែវ-ផន កើតឆ្នាំពេន អាយុ ៤៩ វស្សា ៨ នាមឆាយា សុវណ្ណជោត ជាចៅអធិការ វត្តសុគីសួស្តី ឃុំធក ស្រុកទ្រាំង (តាកែវ) ។

១០ - សញ្ញាប័ត្រលេខ ៦០ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូញាណ-ថៀម កើតឆ្នាំពេន អាយុ ៥៣ វស្សា ៣៣ នាមឆាយា ធម្មត្ថេរ ជាចៅអធិការ វត្តពោធិ៍ចិន ឃុំពោធិ៍ចិន ស្រុកកំពង់សោម (កំពត) ។

១១ - សញ្ញាប័ត្រលេខ ៦១ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូជួក-សម កើតឆ្នាំមមែ អាយុ ៣៨ វស្សា ១៧ នាមឆាយា ឥន្ទត្ថេរ ជាចៅអធិការ វត្តសុវណ្ណរង្សី ឃុំរលាប្អៀរ ស្រុករលាប្អៀរ (កំពង់ឆ្នាំង) ។

១២ - សញ្ញាប័ត្រលេខ ៦២ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូ មូ-សួស កើតឆ្នាំមមែ អាយុ ២៦ វស្សា ៥ នាមធាយា ឥន្ទប្បញ្ញា ជាចៅអធិការ វត្តអន់ផ្អើត ឃុំដីវ ស្រុកកំពង់សោម (កំពត) ។

១៣ - សញ្ញាប័ត្រលេខ ៦៣ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូ ជ័យ-គង់ កើតឆ្នាំមមែ អាយុ ៨២ វស្សា ៦០ នាមធាយា សុវណ្ណសរ ជាចៅអធិការ វត្តកំលត ឃុំពោធិ៍បឹង ស្រុកកំពង់សោម (កំពត) ។

១៤ - សញ្ញាប័ត្រលេខ ៦៤ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូជឹម- អ៊ុល កើតឆ្នាំម្សាញ់ អាយុ ២៨ វស្សា ៧ នាមធាយា ធម្មប្បញ្ញា ជាចៅ- អធិការ វត្តជ្រយត្រាច ឃុំគោកបន្ទាយ ស្រុកលោប្អៀ (កំពង់ឆ្នាំង) ។

១៥ - សញ្ញាប័ត្រលេខ ៦៥ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូទង- គាត កើតឆ្នាំរកា អាយុ ៣៥ វស្សា ១៤ នាមធាយា សុវណ្ណត្ថេរ ជាចៅ- អធិការ វត្តពោធិ៍គិរី ឃុំថ្មស ស្រុកកំពង់សោម (កំពត) ។

១៦ - សញ្ញាប័ត្រលេខ ៦៦ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូអ៊ុង- កាក់ កើតឆ្នាំមមី អាយុ ៥១ វស្សា ២៩ នាមធាយា សុវណ្ណវិន័យ ជាចៅ អធិការ វត្តគិរីសាគរ ឃុំថ្មស ស្រុកកំពង់សោម (កំពត) ។

១៧ - សញ្ញាប័ត្រលេខ ៦៧ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូ មាស-ប៊ុន កើតឆ្នាំរកា អាយុ ៤៨ ឆ្នាំ វស្សា ២៧ នាមធាយា គម្ភីរប្បញ្ញា ជាចៅអធិការ វត្តដីវ ឃុំដីវ ស្រុកកំពង់សោម (កំពត) ។

១៨ - សញ្ញាប័ត្រលេខ ៦៨ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូ ចិក-សុក កើតឆ្នាំរកា អាយុ ៣៥ វស្សា ៨ នាមឆាយា បញ្ញាសរ ជាចៅអធិការ វត្តពលគូប ឃុំដីជាត ស្រុកកំពង់សោម (កំពត) ។

១៩- សញ្ញាប័ត្រលេខ ៦៩ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូទន់-ញៀប កើតឆ្នាំជូត អាយុ ៤៤ វស្សា ២១ នាមឆាយា បញ្ញាកេសរ ជាចៅអធិការ វត្តអន្តគោគ ឃុំដងរែង ស្រុកកំពង់សោម (កំពត) ។

២០- សញ្ញាប័ត្រលេខ ៧០ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូនាន់-ញៀប កើតឆ្នាំម្សាញ់ អាយុ ២៨ វស្សា ៦ នាមឆាយា ហកសាថេរ ជាចៅអធិការ វត្តកណ្តាល ឃុំដីជាត ស្រុកកំពង់សោម (កំពត) ។

២១- សញ្ញាប័ត្រលេខ ៧១ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូ ម៉ុ-ជៀប កើតឆ្នាំមមែ អាយុ ៥១ វស្សា ១៨ នាមឆាយា ខេសរគោរត្រ ជាចៅអធិការ វត្តគិរីបទុម ឃុំដីជាត ស្រុកកំពង់សោម (កំពត) ។

២២- សញ្ញាប័ត្រលេខ ៧២ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូញ៉ែម-អ៊ួន កើតឆ្នាំរកា អាយុ ៣៦ វស្សា ១៦ នាមឆាយា សុវណ្ណបញ្ញា ជាចៅអធិការ វត្តអូរស្វែង ឃុំដំណាក់កន្ទួត ស្រុកកំពង់ត្រាច (កំពត) ។

២៣- សញ្ញាប័ត្រលេខ ៧៣ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូមូល-ឈួន កើតឆ្នាំម្សាញ់ អាយុ ២៨ វស្សា ៧ នាមឆាយា ជយបញ្ញា ជាចៅអធិការ វត្តស្រែត្រាវ ឃុំថ្នស ស្រុកកំពង់សោម (កំពត) ។

៣៤ — សញ្ញាប័ត្រលេខ ៨៤ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូ អ៊ិន-សាំង កើតឆ្នាំរោង អាយុ ៣៧ វស្សា ១៧ នាមឆាយា ចន្ទសារ ជាចៅអធិការ វត្តដងទង់ ឃុំស្វាយទង ស្រុកកំពង់ត្រាច (កំពត) ។

៣៥-សញ្ញាប័ត្រលេខ ៨៥ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូហួត-ឆាយ កើតឆ្នាំមមី អាយុ ៦៣ វស្សា ៤២ នាមឆាយា ចន្ទសរ ជាចៅអធិការ វត្តក្រាំងលាវ ឃុំស្រែជា ស្រុកកំពង់ត្រាច (កំពត) ។

៣៦-សញ្ញាប័ត្រលេខ ៨៦ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូម៉ែន-ញៀក កើតឆ្នាំជូត អាយុ ៣២ វស្សា ១២ នាមឆាយា ព្រហ្មជោត ជាចៅអធិការ វត្តព្រៃខ្ពស់ ឃុំស្រែជា ស្រុកកំពង់ត្រាច (កំពត) ។

៣៧- សញ្ញាប័ត្រលេខ ៨៧ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូ កុប ម៉ាត កើតឆ្នាំមមី អាយុ ៣៨ វស្សា ១៣ នាមឆាយា ធម្មសារ ជាចៅអធិការ វត្តអន្លង់ដំបងដែក ឃុំស្វាយទង ស្រុកកំពង់ត្រាច (កំពត) ។

៣៨ - សញ្ញាប័ត្រលេខ ៨៨ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូ សៅ-សេង កើតឆ្នាំរក អាយុ ៣៧ វស្សា ១៥ នាមឆាយា ចន្ទសុ ជាចៅអធិការ វត្តជួបបុណ្យ ឃុំស្វាយទង ស្រុកកំពង់ត្រាច (កំពត) ។

៣៩ - សញ្ញាប័ត្រលេខ ៨៩ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូ ខូប-ចេង កើតឆ្នាំច អាយុ ២៣ វស្សា ៤ នាមឆាយា មង្គលតេជោ ជាចៅអធិការ វត្តដងទង់ ឃុំស្វាយទង ស្រុកកំពង់ត្រាច (កំពត) ។

៤០- សញ្ញាប័ត្រលេខ ៩០ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូ ត្រី-អន កើតឆ្នាំកុរ អាយុ ៣៤ វស្សា ៥ នាមឆាយា សុវណ្ណ-ត្ថេរ ជាចៅអធិការ វត្តគងជុំវិញ ឃុំដងពែង ស្រុកកំពង់សោម (កំពត) ។

៤១ - សញ្ញាប័ត្រលេខ ៩១ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូ កែវ-អុំ កើតឆ្នាំរោង អាយុ ៤១ វស្សា ២០ នាមឆាយា សង្ឃរក្ខិត ជាចៅអធិការ វត្តអង្គជី ឃុំបឹងសាលា ស្រុកកំពង់ត្រាច (កំពត) ។

៤២- សញ្ញាប័ត្រលេខ ៩២ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូ ង៉ែត-សូរ កើតឆ្នាំខាល អាយុ ៦៧ វស្សា ៤៦ នាមឆាយា សុវណ្ណកេសី ជាចៅអធិការ វត្តស្រែជា ឃុំស្រែជា ស្រុកកំពង់ត្រាច (កំពត) ។

៤៣- សញ្ញាប័ត្រលេខ ៩៣ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូ សៅ-ឡេង កើតឆ្នាំមមែ អាយុ ៣៨ វស្សា ១៨ នាមឆាយា ឥន្ទសរ ជាចៅអធិការ វត្តអរញ្ញគិរី ឃុំឫស្សីស្រុក ស្រុកកំពង់ត្រាច (កំពត) ។

៤៤- សញ្ញាប័ត្រលេខ ៩៤ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូ ម៉ុច-យ៉ែម កើតឆ្នាំរកា អាយុ ៣៦ វស្សា ១៥ នាមឆាយា ពុទ្ធរក្ខិត ជាចៅអធិការ វត្តព្រះគោ ឃុំ- ស្រុកកំពង់ត្រាច (កំពត) ។

៤៥- សញ្ញាប័ត្រលេខ៩៥ចុះថ្ងៃ៩-៨-៤៤ តាំងលោកគ្រូអ៊ុំង-សាក់ កើតឆ្នាំកា អាយុ ២៤ វស្សា ៤ នាមឆាយា សទ្ធវឌ្ឍិត ជាចៅ-អធិការ វត្តអន្លង់ចម ឃុំដំណាក់កន្ទួត ស្រុកកំពង់ត្រាច (កំពត) ។

៤៦ - សញ្ញាប័ត្រលេខ ៩៦ ចុះថ្ងៃ ២១-៨- ៤៤ តាំងលោកគ្រូប៉ាក់ជិន កើតឆ្នាំមមែ អាយុ ២៦ វស្សា ៤ នាមឆាយា-សោភិតោ ជាចៅអធិការ វត្តត្រពាំងថ្លៃ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ (កំពង់ធំ) ។

៤៧ - សញ្ញាប័ត្រលេខ ៩៧ ចុះថ្ងៃ ២៣-៨-៤៤ តាំងលោកគ្រូថង-ធីង កើតឆ្នាំម្សាញ់ អាយុ ២៨ វស្សា ៧ នាមឆាយា ឥន្ទវង្ស ជាចៅអធិការ វត្តមគ្គោ ឃុំព្រែកខ្សាប់ ស្រុកកោះកុង (កំពត) ។

៤៨ - សញ្ញាប័ត្រលេខ ២ ចុះថ្ងៃ ២៨-៨-៤៤ តាំងលោកគ្រូពុត-ហោម កើតឆ្នាំក អាយុ ៣៦ វស្សា ១៦ នាមឆាយា បញ្ញាសីលោ ជាចៅអធិការ វត្តខ្នុរង ឃុំស្វាយយារ (គណធម្មយុត្តិ) ស្រុកស្វាយទាប (ស្វាយរៀង) ។

៤៩ - សញ្ញាប័ត្រលេខ ៩៨ ចុះថ្ងៃ ៣១-៨-៤៤ តាំងលោកគ្រូគោត-ពីន់ កើតឆ្នាំម្សាញ់ អាយុ ៥២ វស្សា ៣០ នាមឆាយា ធម្មត្ថេរ ជាចៅអធិការ វត្តខ្ទួលសន្ធារ ឃុំញ្ញោ ស្រុកសន្ទុក (កំពង់ធំ) ។

## ឯកកភាគនៃមិលិន្ទបញ្ហា

ហួងនិពន្ធមន្ត្រី រួបរួមប្រែពីគម្ពីរមិលិន្ទបញ្ហា

(តទៅ)

## អង្គ ២ របស់ជាងចាំង:

១. ចាំងឈើតាមខ្សែបន្ទាត់ ។

២. ចាំងយកសាច់សំបកស្រាយចេញទុកតែខ្លឹម ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ២ ប្រការគឺ:

១-ប្រតិបត្តិអនុលោមទៅតាមពាក្យប្រៀនប្រដៅរបស់សម្តេចព្រះជិនស្រីឈរលើផែនដី គឺសីល ចាប់កាន់ពូថៅ គឺបញ្ញា ដោយដៃគឺសទ្ធា ហើយចាំងកិលេសទាំងឡាយឲ្យស្រួតហួតហែងទៅចាកខន្ធសន្តាន ។

២-លះបង់ចោលមិច្ឆាទិដ្ឋិ ដូចជាសាច់ស្រាយ ដែលមានសស្សតទិដ្ឋិនិងឧច្ឆេទទិដ្ឋិជាដើមចេញ រើសយកតែធម៌ដែលមានខ្លឹមសារប៉ុណ្ណោះ ។

## អង្គ ២ របស់ថ្នាំរម្ងាប់ពិស:

១-មិនមានដង្កូវកើតឡើងក្នុងថ្នាំពិស ។

២-រម្ងាប់ពិសបានគ្រប់យ៉ាង ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយគុណសម្បត្តិ ២ ប្រការ គឺ:

១-មិនបង្កកិលេសដូចជាដង្កូវឲ្យកើតឡើងក្នុងចិត្ត ។

២-កំចាត់រាគ: ទោស: មាន: ទិដ្ឋិ ដូចជាពិសចោលចេញ ។

ពួកមានអង្គ ៣

## អង្គ ៣ របស់ផ្កាឈូក:

១— ដុះឡើងក្នុងទឹក ធំធាត់ឡើងក្នុងទឹក តែមិនជាប់ទឹកឡើយ ។

២— ដុះផុតអំពីទឹកក៏អណ្តែតនៅលើទឹក ។

៣— ត្រូវខ្យល់បក់តែបន្តិចបន្តួច ក៏ញោយសន្ទុះយោកយោកទៅមក ។

ប្រៀបដូចអ្នកប្រតិបត្តិ ប្រកបដោយអង្គសម្បត្តិ ៣ ប្រការគឺ

១— មិនជាប់ចិត្តនឹងត្រកូលនឹងពួកគណៈ លាភ យស សរសើរ សុខ ហើយនឹងបច្ច័យជាគ្រឿងបរិភោគទាំងឡាយ ដកបដល់មិនជាប់ជំពាក់ ដោយកិលេសទាំងអស់ ។

២— គ្របសង្កត់លោកធម៌ទាំងពួងបានហើយ ដុះអណ្តែតនៅក្នុងលោកុត្តរធម៌ ។

៣— តាំងសង្រួមចិត្តមិនឲ្យធ្លាក់ទៅក្នុងកិលេស សូម្បីតែបន្តិចបន្តួចក៏ដោយ មានប្រក្រតីឃើញកិលេសបន្តិចបន្តួចជាសភាពគួរខ្លាចជានិច្ច ។

## អង្គ ៣ របស់ពៅ :

១— ផ្ទុកជនជាច្រើនឲ្យបានឆ្លងទៅដល់ត្រើយ ។

២— តម្រល់ត្រាំទ្រនឹងកំឡាំងទឹករលកបោកបក់នឹងខ្យល់ទឹកហូរឬខ្យល់ទឹកតែលែរលំបាន ។

៣ — បើកចេញទៅក្នុងមហាសមុទ្រ ដ៏ធំធេងមានជំរៅជ្រៅពន្លឹក ដ៏ដេរដាសដោយហ្វូងមច្ឆាតូចធំជាច្រើន ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៣ ប្រការគឺ :

១ — បម្រុងជញ្ជូនសត្វក្នុងមនុស្សលោក ព្រមទាំងទេវលោកឲ្យបានឆ្លងដល់ត្រើយ ដោយអំណាចសេចក្តីព្រមព្រៀងនៃគុណធម៌ទុកដូចជានាវា គឺសីលគុណនិងវត្តប្រតិបត្តិជាដើម ។

២ — អត់ទ្រាំតទល់នឹងកំឡាំងកិលេស គឺលោកធម៌ទាំង ៨ ប្រការ ដែលមានឧបមាដូចរលកទឹក ។

៣ — ខ្វល់ខ្វាយកសាងបារមី ដែលជាសេចក្តីប្រតិបត្តិបង្អោនទៅរកសញ្ញាណទាំង ១០ ប្រការ ធ្វើចិត្តឲ្យត្រាច់ទៅក្នុងអរិយសច្ច ៤ មានបរិវដ្ត ៣ មានអាការ ១២ ។

## អង្គ ៣ របស់នាយសំពៅ :

១ — មានស្មារតីល្អមិនធ្វេសប្រហែស ទាំងយប់ទាំងថ្ងៃ ចាំគន់ថែរក្សាត្រួតត្រាសំពៅ ។

២ — ផ្លូវដើរទឹកគ្រប់ទិស នាយសំពៅត្រូវតែដឹងសព្វអន្លើក្នុងមហាសមុទ្រនោះ ទុកជាផ្លូវមានគ្រោះថ្នាក់ឬគ្មាន នាយសំពៅក៏ត្រូវដឹងទាំងអស់ ។

៣ — តាំងត្រៃស័យដោយខ្លួនឯង មិនឲ្យអ្នកដទៃមកប៉ះពាល់ប្រយ័ត្នសំពៅ មិនឲ្យមានអន្តរាយ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៣ ប្រការគឺ

១ — ជាអ្នកមិនប្រមាទទាំងយប់ទាំងថ្ងៃជានិច្ច ទប់ទល់ចិត្តដោយយោនិសោមនសិការៈ ។

២ — បេះដឹងច្បាស់លាស់នូវធម៌ទាំងឡាយ ដែលជាកុសលអកុសល មានទោសឥតទោសដែលគួរសេពមិនគួរសេព អាក្រក់នឹងល្អ ជាកណ្ហធម៌ ទិនសុក្កធម៌ ។

៣ — តាំងចិត្តសង្រួមដូចជាត្រៃស័យរក្សាចិត្ត ហាមចិត្តមិនឲ្យត្រេះត្រះទៅក្នុងអកុសលវិតក្ក សូម្បីជាអំពើលាមកបន្តិចបន្តួចក៏ដោយ ។

## អង្គ ៣ របស់ព្រះឥន្ទ្រៈ

១ — ពោរពេញទៅដោយសេចក្ដីសុខជាទីបំផុត ។

២ — ជាកំពូលនៃទេវតាទាំងឡាយ ៗ តែងលើកសរសើរនាំឲ្យកើតសេចក្ដីសប្បាយរីករាយយ៉ាងវិសេសវិសាល ។

៣ — មិនដែលកើតចិត្តនឿយណាយក្នុងទិព្វសម្បត្តិ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៣ ប្រការគឺៈ

(មានត)

[stamp]